# ការវិភាគអំពីច្បាប់បរិស្ថានអន្តរជាតិពាក់ព័ន្ធនឹង សេចក្តីសម្រេចចិត្តក្នុងការអនុម័តគម្រោងសាងសង់ទំនប់សាយ៉ាប៊ូរី

## សម្រាប់អង្គការទន្លេអន្តរជាតិ
## និងមជ្ឈមណ្ឌលច្បាប់ដើម្បីអ្នកការពារបរិស្ថាន

**រៀបចំដោយ** Steve Higgs
**ការិយាល័យមេធាវី** Perkins Coie LLP

**ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១១**

# សេចក្តីផ្តើម និងសេចក្តីសង្ខេប

សេចក្តីសន្និដ្ឋាននេះជាការវិភាគផ្នែកច្បាប់ដោយពិនិត្យលើច្បាប់ស្តីពីបរិស្ថានមួយចំនួន និងការទទួលខុសត្រូវនានា ដែលមានពាក់ព័ន្ធនឹងការសម្រេចចិត្តរបស់សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវក្នុងការអនុម័តគម្រោងទំនប់វារីអគ្គិសនីសាយ៉ាបួរី (ហៅកាត់ថា ទំនប់សាយ៉ាបួរី) នៅលើទន្លេមេគង្គក្រោម។

សំណើទំនប់វារីអគ្គិសនីសាយ៉ាបួរី តាមបទដ្ឋានពិភពលោក ត្រូវចាត់ទុកថាជា "ទំនប់ធំ" ដោយមាន កម្ពស់ជិត ៥០ម៉ែត្រ ទទឹង៨៣០ម៉ែត្រ និងមានអាងស្តុកទឹកមួយមានជម្រៅរហូតជិត៣០ម៉ែត្រ និងលាតសន្ធឹង ទៅទន្លេលើពី៦០ទៅ៩០គីឡូម៉ែត្រ។[១] ទំនប់ធំៗតែងតែមានផលប៉ះពាល់ធំធេងដែលគេត្រូវតែគិត វិភាគ ផ្សព្វផ្សាយ និងកាត់បន្ថយទុកជាមុន មុននឹងចាប់ផ្តើមដំណើរការសាងសង់។ ទាំងអស់នេះជាលក្ខខណ្ឌនៃអភិបាលកិច្ចល្អ និងនៃច្បាប់បរិស្ថានអន្តរជាតិដែលត្រូវអនុវត្ត នៅពេលដែលរដ្ឋាភិបាលណាមួយស្នើសុំអភិវឌ្ឍគម្រោងថាមពលធំៗ ដែលអាចបណ្តាលឱ្យមានផលប៉ះពាល់បរិស្ថានឆ្លងដែន និងបង្កឱ្យមានការលំបាកដល់ការរស់នៅរបស់ប្រជាជន។

យើងទទួលស្គាល់ សារសំខាន់នៃការអភិវឌ្ឍប្រកបដោយនិរន្តរភាពរបស់សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងតួនាទីនៃការផលិតថាមពលដែលអាចផ្តល់ភាពងាយស្រួលដើម្បីសម្រេចគោលបំណងនេះ។ ប៉ុន្តែដំណើរឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយនិរន្តរភាពតម្រូវថា ការសម្រេចចិត្តអំពីការអភិវឌ្ឍរបស់រដ្ឋាភិបាល ត្រូវតែមានការវិភាគយ៉ាងល្អិតល្អន់ មានការវាយតម្លៃយ៉ាងគ្រប់ជ្រុងជ្រោយ និងប្រកាសជាសាធារណៈ អំពីផលប៉ះពាល់លើបរិស្ថាននិងសង្គម និងត្រូវតែមានសំណើសុីវិធានការកាត់បន្ថយផលប៉ះពាល់ដែលគេដឹងថា អាចនឹងកើតមាន និងមានសំណើសមហេតុសមផលអាចអនុវត្តបាន។

ប៉ុន្តែគួរឱ្យសោកស្តាយ ដូចបានសង្ខេបជូនថា តាមការវាយតម្លៃរបស់អ្នកវិទ្យាសាស្ត្រ និងអ្នកឯកទេសឯករាជ្យ បានបង្ហាញថា ចំពោះគម្រោងទំនប់សាយ៉ាបួរីនេះរដ្ឋាភិបាលឡាវ ពិតជាខកខានមិនបានបំពេញតាមលក្ខខណ្ឌជាមូលដ្ឋានទាំងនេះទេ និងដោយគ្មានការវិភាគនិងការពិគ្រោះយោបល់បន្ថែម ដូច្នេះវាពិតជាមិនអាចបំពេញលក្ខខណ្ឌទាំងនោះបានទេ។ ការវាយតម្លៃផលប៉ះពាល់បរិស្ថានរបស់គម្រោង ដែលគួរបង្កើតបានជាមូលដ្ឋាននៃការវាយតម្លៃគម្រោងយ៉ាងច្បាស់លាស់នោះ មិនគ្រប់ជ្រុងជ្រោយ និងមិនពេញលេញទេ។ សំណើសាងសង់ជណ្តើរសម្រាប់ត្រី មិនសមប្រកបនឹងបរិមាណត្រីច្រើនដែលត្រូវរស់នៅក្នុងតំបន់ផលប៉ះពាល់នៃទំនប់នោះទេ រីឯអ្នក

ឯកទេសវិញបានសន្និដ្ឋានថា គម្រោងនេះអាចបណ្តាលឱ្យប្រភេទត្រីសំខាន់ៗងាប់ផុតពូជទាំងស្រុង ដែលទន្ទឹមគ្នានោះដែរ ធ្វើឱ្យត្រីផ្សេងៗទៀតធ្លាក់ចូលក្នុងស្ថានភាពគ្រោះថ្នាក់រហូតផុតពូជ។ រដ្ឋាភិបាលនៃប្រទេសជិតខាងដែលប្រើទន្លេរួមគ្នា ដូចជា ប្រទេសកម្ពុជា ថៃ និងប្រទេសវៀតណាម បានសម្តែងក្តីបារម្ភរៀងៗខ្លួន ឬរៀបរាប់អំពីក្តីបារម្ភរបស់ភាគីពាក់ព័ន្ធរបស់ខ្លួនថា ផលប៉ះពាល់ដែលបង្កឡើងដោយទំនប់នេះនឹងបណ្តាលឱ្យមានផលប៉ះពាល់បរិស្ថានឆ្លងដែនមិនអាចសម្រាលបាន នៅក្នុងដែនសមត្ថកិច្ចរៀងៗខ្លួន។ វាពិតជាសំខាន់ណាស់ដែលត្រូវបំពេញតាមលក្ខខណ្ឌបរិស្ថានអន្តរជាតិសម្រាប់គម្រោងនេះ ពីព្រោះទំនប់សាយ៉ាប៊ូរីគឺជា ទំនប់ទី១ក្នុងចំណោមសំណើទំនប់ទាំង១១ នៅលើដងទន្លេមេគង្គក្រោម ដែលជាទន្លេឆ្លងដែនសំខាន់បំផុតចំពោះបណ្តាប្រទេសជិតខាង និងសហគមន៍អន្តរជាតិ។

តុលាការយុត្តិធម៌អន្តរជាតិ បានពន្យល់អំពីគោលការណ៍យ៉ាងសំខាន់របស់ច្បាប់ស្តីពីបរិស្ថានអន្តរជាតិដូចខាងក្រោមនេះ:

> បរិស្ថានមិនមែនអរូបកម្មទេ ប៉ុន្តែជាលំហសម្រាប់ជីវិត ជាលក្ខខណ្ឌនៃជីវិត និងសុខភាពរបស់មនុស្សជាតិរួមទាំងមនុស្សដែលមិនទាន់កើតផង។ អត្ថិភាពនៃកាតព្វកិច្ចជាទូទៅរបស់ប្រទេសនីមួយៗក្នុងការធានាថាសកម្មភាពគម្រោងទាំងឡាយនៅក្នុងដែនសមត្ថកិច្ច និងការគ្រប់គ្រងរបស់ខ្លួន គោរពបរិស្ថានរបស់ប្រទេសផ្សេងៗ ឬរបស់តំបន់ដែលស្ថិតនៅក្រៅការគ្រប់គ្រងថ្នាក់ជាតិ ដែលជាផ្នែកនៃបណ្តុំច្បាប់អន្តរជាតិដែលពាក់ព័ន្ធនឹងបរិស្ថាន។[២]

សេចក្តីសន្និដ្ឋាននេះ នឹងបង្ហាញអំពីគោលការណ៍នេះតាមរយៈច្បាប់បរិស្ថានអន្តរជាតិចំនួនប្រាំចំណុចដែលសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវមាន ឬអាចរំលោភបំពានប្រសិនបើ ប្រទេសនេះ អនុញ្ញាតដំណើរការសាងសង់ទំនប់សាយ៉ាប៊ូរី តាមការស្នើសុំ ដោយមិនធ្វើការវាយតម្លៃផលប៉ះពាល់បរិស្ថានឡើងវិញ ដោយមិនចាប់ផ្តើមដំណើរការនៃការពិគ្រោះយោបល់ និងការចូលរួមជាសាធារណៈ ដោយមិនវាយតម្លៃនិងរៀបចំឯកសារអំពីផលប៉ះពាល់ឆ្លងដែនដែលអាចនឹងកើតឡើងដោសារគម្រោងទំនប់នេះ និងដោយមិនផ្តល់ឱកាសជូនរដ្ឋាភិបាលនៃប្រទេសទាំងបី នៅតាមដងទន្លេមេគង្គក្រោមដើម្បីអនុវត្ត ដំណើរការនៃនីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ និងការព្រមព្រៀងជាមុន ទៅតាមកិច្ចព្រមព្រៀងនៃគណៈកម្មការទន្លេមេគង្គទេ។[៣] យើងនឹងបង្ហាញប្រាំមួយចំណុចនៃច្បាប់ ដើម្បីបំភ្លឺអំពីអង្គហេតុដែលរដ្ឋាភិបាលនៃប្រទេសបីទៀត នៅតាមដងទន្លេមេគង្គ (គឺប្រទេសកម្ពុជា ថៃ និងវៀតណាម) មានសិទ្ធិនិងកាតព្វកិច្ចដូចគ្នា ក្នុងកិច្ចការពារការប្រើទន្លេមេគង្គរួមគ្នា។

ជាសេចក្តីសង្ខេប ការពិនិត្យរបស់យើងលើច្បាប់បរិស្ថានអន្តរជាតិ និងការសន្ទតអង្គហេតុដែលបញ្ជាក់នៅទីនេះ[៤] ឈានទៅដល់សេចក្តីសន្និដ្ឋានដូចខាងក្រោមនេះ:

១. ការវាយតម្លៃផលប៉ះពាល់បរិស្ថានសម្រាប់ទំនប់សាយ៉ាប៊ូរីគប្បីត្រូវធ្វើឡើងវិញ ដើម្បីបំពេញលក្ខខណ្ឌនៃបទដ្ឋានអន្តរជាតិសម្រាប់ទំនប់ខ្នាតធំដែលត្រូវសាងសង់លើទន្លេឆ្លងដែន ដែលត្រូវមានបញ្ចូលរបាយការណ៍ស្តីពីការវិភាគលម្អិតអំពីផលប៉ះពាល់ឆ្លងដែនដែលអាចនឹងកើតឡើងដោយគម្រោងនេះ។

២. ដោយសារតែ ការវាយតម្លៃផលប៉ះពាល់បរិស្ថានមានចំណុចខ្វះខាត និងមិនបានប្រកាសជាសាធារណៈមុនដំណើរការនៃការចូលរួម និងពិគ្រោះយោបល់ជាសាធារណៈ ដូច្នេះដំណើរការនៃការវាយតម្លៃនោះ ពិតជាធ្វើឱ្យខូចការយ៉ាងធ្ងន់ធ្ងរ។ នៅពេលដែលការវាយតម្លៃផលប៉ះពាល់បរិស្ថានត្រូវបានបញ្ចប់ហើយនោះ ការវិភាគនោះគួរតែបង្កើតបានជាមូលដ្ឋានសម្រាប់ការចូលរួម និងពិគ្រោះយោបល់ជាសាធារណៈ អំពីទំនប់នៅក្នុងប្រទេសឡាវ និងប្រទេសបីទៀតដែលស្ថិតនៅតាមដងទន្លេមេគង្គក្រោម។

៣. សេចក្តីសម្រេចចិត្តក្នុងការអនុម័តគម្រោងទំនប់សាយ៉ាប៊ូរី តាមការស្នើសុំនោះ នឹងបណ្តាលឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ប្រព័ន្ធជីវសិរីវាង្គចម្រុះដែលប្រើរួមគ្នាដោយប្រទេសផ្សេងៗទៀត ដោយបំពានកាតព្វកិច្ចរបស់សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ក្រោមអនុសញ្ញាស្តីពីប្រព័ន្ធជីវសិរីវាង្គចម្រុះ។

៤. សេចក្តីសម្រេចចិត្តក្នុងការអនុម័តគម្រោងទំនប់សាយ៉ាប៊ូរី តាមការស្នើសុំនោះ នឹងបណ្តាលឱ្យមានគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរដល់ប្រទេសជិតខាង ដោយសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវរំលោភកាតព្វកិច្ចរបស់ខ្លួន ក្នុងកិច្ចការពារគ្រោះថ្នាក់ឆ្លងដែន។

៥. សេចក្តីសម្រេចចិត្តក្នុងការអនុម័តគម្រោងទំនប់សាយ៉ាប៊ូរី តាមការស្នើសុំនោះ រំលោភបំពានគោលការណ៍គិតបង្ការទុកមុន ព្រោះសេចក្តីសម្រេចចិត្តនោះខកខានមិនបានដោះស្រាយភាពមិនច្បាស់លាស់ចំពោះមុខ និងក្តីកង្វល់អំពីផលប៉ះពាល់ដោយសារទំនប់នោះទេ ព្រមទាំងខកខានមិនបានបង្ហាញថា សំណើកាត់បន្ថយផលប៉ះពាល់ទាំងនេះអាចនឹងដំណើរការទៅមុខដោយជោគជ័យនោះឡើយ។

៦. ប្រទេសកម្ពុជា ថៃ និងប្រទេសវៀតណាម មានសិទ្ធិនិងកាតព្វកិច្ចត្រូវការពារកុំឱ្យមានផលប៉ះពាល់ ដល់ទន្លេមេគង្គ ដោយសារទំនប់សាយ៉ាប៊ូរី។ រដ្ឋាភិបាលនៃប្រទេសទាំងបីនេះ មានសិទ្ធិទទួលដំណោះស្រាយផ្នែកហិរញ្ញវត្ថុ សម្រាប់ផលប៉ះពាល់ធ្ងន់ធ្ងរដែលកើតមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន រៀងៗខ្លួន។

ចំណុចទាំងប្រាំមួយខាងលើនេះ អាចបង្ហាញអំពីស្ថានភាពមួយចំនួនសម្រាប់កិច្ចពិគ្រោះយោបល់ជាផ្លូវការ នៅក្នុងខែវិច្ឆិកាខាងមុខនេះ ដែលយើងដឹងថា គណៈកម្មការទន្លេមេគង្គ មានគម្រោងជួបប្រជុំ ដើម្បីពិភាក្សាអំពីដំណើរការនៃនីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ និងការយល់ព្រមជាមុន ដែលត្រូវអនុវត្តចំពោះគម្រោងទំនប់សាយ៉ាប៊ូរី ព្រមទាំងពិភាក្សាថា តើអាចឬមិនអាចសាងសង់ទំនប់នេះ។ ដើម្បីជាជំនួយដល់កិច្ចពិគ្រោះយោបល់នេះ យើងនឹងបញ្ចប់សេចក្តីសន្និដ្ឋានផ្នែកច្បាប់នេះ ដោយផ្តល់អនុសាសន៍បី ដែលរដ្ឋាភិបាលណាមួយ ឬទាំងអស់អាចយកទៅអនុវត្តដើម្បីដោះស្រាយវិវាទពាក់ព័ន្ធនឹងបញ្ហាដែលថា តើទំនប់នេះត្រូវសងសង់ដែរឬទេ ឬថាតើត្រូវសាងសង់ទំនប់នេះដោយរបៀបណា។

ពេលនេះ យើងសូមបញ្ជាក់អំពីចំណុចកត់សម្គាល់គួរប្រុងប្រយ័ត្នពីរ ពាក់ព័ន្ធនឹងការប្រើការវិភាគតាមច្បាប់នេះ។ ទី១ ការវិភាគនេះលើកឡើងអំពីកាតព្វកិច្ចជាច្រើនរបស់សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ពាក់ព័ន្ធនឹងបរិស្ថានអន្តរជាតិ ប៉ុន្តែ មិនលើកឡើងទាំងអស់ទេ រួមទាំងកាតព្វកិច្ចទាំងអស់ដែលស្ថិតក្រោមកិច្ចព្រមព្រៀងទន្លេមេគង្គ ឬសិទ្ធិមនុស្សផង ថែមទាំងមិនផ្តោតលើច្បាប់ថ្នាក់ជាតិរបស់សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ឬរបស់ប្រទេសទាំងបីដែលស្ថិតនៅតាមដងទន្លេមេគង្គទេ។ ពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងទន្លេមេគង្គ លិខិតរបស់យើងចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១១ បានបំភ្លឺអំពីការទទួលខុសត្រូវដែលពាក់ព័ន្ធយ៉ាងច្បាស់ជាច្រើនរបស់សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដែលតាមទស្សនៈរបស់យើង គួរត្រូវពិចារណាលើច្បាប់ជាមូលដ្ឋានដើម្បីអនុវត្តក្នុងការដោះស្រាយវិវាទពាក់ព័ន្ធនឹងទន្លេឆ្លងដែននេះ។[៥] ពាក់ព័ន្ធនឹងច្បាប់សំខាន់ៗផ្សេងទៀត ដែលអាចអនុវត្តបាននោះ មានច្រើនណាស់ដែលទំនងជាសមស្រប ប្រសិនបើ និងនៅពេលដែលផលប៉ះពាល់បរិស្ថាន ឬសេដ្ឋកិច្ច-សង្គមកើតមាន។

ទី២ មានតម្រូវការជាបន្ទាន់ដើម្បីធ្វើការវាយតម្លៃបន្ថែមដោយទីប្រឹក្សាទីបី អំពីអង្គហេតុពាក់ព័ន្ធ ដើម្បីអនុវត្តច្បាប់នោះ ព្រោះថា ការអនុវត្តច្បាប់គឺដំណើរការទៅមុខដោយមានអង្គហេតុ។ យើងនៅមិនទាន់បានបំពេញការងាររបស់យើងផ្ទាល់ក្នុងការពិនិត្យយ៉ាងល្អិតល្អន់លើ ការវាយតម្លៃអំពីផលប៉ះពាល់បរិស្ថាននោះ ដើម្បីកំណត់ថាតើការវាយតម្លៃនេះ ឬឯកសារពាក់ព័ន្ធនឹងការសម្រេចចិត្តគម្រោងផ្សេងទៀតស្របនឹងលក្ខខណ្ឌអន្តរជាតិសម្រាប់ទំនប់ខ្នាតធំដែរឬទេ។ ផ្ទុយទៅវិញ យើងជឿលើការវាយតម្លៃផលប៉ះពាល់បរិស្ថានជាលាយលក្ខណ៍អក្សរដោយអ្នកវិទ្យាសាស្ត្រ និងអ្នកមានវិជ្ជាជីវៈ[៦] ក៏ដូចជា លើរបាយការណ៍ពិនិត្យឡើងវិញលើការពិគ្រោះយោបល់គម្រោងជាមុន របស់លេខាធិការដ្ឋាននៃគណៈកម្មការទន្លេមេគង្គដែរ។[៧] អនុសាសន៍មួយ ក្នុងចំណោមអនុសាសន៍នានារបស់

យើង ដូចមានបញ្ជាក់ខាងក្រោមនេះ គឺចង់ឱ្យមានការវិភាគកាន់តែឯករាជអំពីឯកសារពាក់ព័ន្ធនឹង ការសម្រេចចិត្តគម្រោងទាំងអស់។ ឧទាហរណ៍ ការធានាថា មានការវិភាគយ៉ាងច្បាស់លាស់លើផលប៉ះពាល់ដែលកើនឡើងដោយសារ គម្រោងនេះ ដោយពិចារណាយ៉ាងល្អិតល្អន់លើ គម្រោងផ្សេងៗទៀតទាំងអស់ដែលស្នើសុំសាងសង់នៅតាមដៃទន្លេ និងទន្លេមេនៃទន្លេមេគង្គ។ ទំនប់ធ្វើឱ្យលក្ខណៈរូប លក្ខណៈជីវៈ និងលក្ខណៈគីមី នៅក្នុងទន្លេមានការផ្លាស់ប្តូរ និងអាច ប៉ះពាល់ដល់បណ្តាសហគមន៍ តាមវិធីយ៉ាងស្មុគស្មាញ ដែលគួរតែត្រូវវាយតម្លៃនិងយល់ឱ្យបានយ៉ាងច្បាស់លាស់ មុននឹងចាប់ផ្តើមសាងសង់។

## កិច្ចពិភាក្សា

**១. ការវាយតម្លៃផលប៉ះពាល់បរិស្ថានសម្រាប់ទំនប់សាយ៉ាប៊ូរី ត្រូវធ្វើឡើងវិញ ដើម្បីបំពេញលក្ខខណ្ឌនៃបទដ្ឋានអន្តរជាតិសម្រាប់ទំនប់ខ្នាតធំដែលត្រូវសាងសង់លើទន្លេឆ្លងដែន ដែលត្រូវមានបញ្ចូលរបាយការណ៍ស្តីពីការវិភាគលម្អិតអំពីផលប៉ះពាល់ឆ្លងដែនដែលអាចនឹងកើតឡើងដោយគម្រោងនេះ ។**

រដ្ឋាភិបាលចាំបាច់ត្រូវតែធ្វើការវិភាគផ្នែកបរិស្ថានឱ្យបានល្អិតល្អន់ ដែលការវិភាគនេះគេហៅថា "ការវាយតម្លៃផលប៉ះពាល់បរិស្ថាន" ។ ភ្នាក់ងារថាមពលអន្តរជាតិកំណត់និយមន័យ "ការវាយតម្លៃផលប៉ះពាល់បរិស្ថាន" ថា:

> ជា ការកំណត់អត្តសញ្ញាណ ការរៀបរាប់ និងការប៉ាន់ប្រមាណអំពីឥទ្ធិពលដោយផ្ទាល់ និងដោយប្រយោលពីគម្រោង លើមនុស្សជាតិ សត្វនិងរុក្ខជាតិ ដី ទឹក ខ្យល់ បរិយាកាស និងទេសភាព អន្តរកម្មរវាងកត្តាទាំងនេះ និងសម្បត្តិសម្ភារៈ និងកេរ្តិ៍ដំណែលវប្បធម៌ ។[៨]

លក្ខខណ្ឌដើម្បីអនុវត្តការវាយតម្លៃផលប៉ះពាល់បរិស្ថានប្រកបដោយផ្លែផ្កា គឺជាកាតព្វកិច្ចជំហានដំបូង តាមច្បាប់អន្តរជាតិ មុននឹងរដ្ឋាភិបាលណាមួយ អាចឈានទៅរកគម្រោងអភិវឌ្ឍន៍ធំៗ ដែលអាចនឹងមានផលអាក្រក់ប៉ះពាល់ឆ្លងដែនលើបរិស្ថាន និងប្រជាជន។ ថ្មីៗនេះ លក្ខខណ្ឌនេះត្រូវបានប្រកាសបញ្ជាក់ឡើងវិញដោយតុលាការយុត្តិធម៌អន្តរជាតិ នៅក្នុងសេចក្តីសម្រេចចិត្តរបស់ខ្លួនកាលពីឆ្នាំ២០១០ ក្នុងគម្រោង *Pulp Mills on the River Uruguay* (ប្រទេសអាហ្សង់ទីន និង ប្រទេសយូរ៉ាហ្គាយ) ថា:

> ឥឡូវនេះអាចចាត់ទុក [ការវាយតម្លៃផលប៉ះពាល់បរិស្ថាន] ជាលក្ខខណ្ឌតាមច្បាប់អន្តរជាតិទូទៅ ក្នុងការអនុវត្តការវាយតម្លៃផលប៉ះពាល់បរិស្ថាន នៅទីណាដែលមានហានិភ័យ ដែលអាចបង្កឱ្យមានផលប៉ះពាល់ឆ្លងដែន យ៉ាងធ្ងន់ធ្ងរ ដោយសំណើសកម្មភាព ឧស្សាហកម្ម ជាពិសេស លើធនធានដែលប្រើរួមគ្នា។ ម្យ៉ាងទៀត វិធានការយ៉ាងសមស្រប និងកាតព្វកិច្ចក្នុងការឃ្លាំមើល និងការទប់ស្កាត់ដែលបានស្នើឡើងនោះ មិនត្រូវបានចាត់ទុកថា បានអនុវត្តទេ ប្រសិនបើ ភាគីធ្វើផែនការដែលទទួលខុសត្រូវចំពោះផលប៉ះពាល់របបទន្លេ ឬគុណភាពនៃទឹកនោះ មិនបានអនុវត្តការវាយតម្លៃផលប៉ះពាល់បរិស្ថានលើផលប៉ះពាល់ធំៗលើការងារបែបនោះទេ។[៩]

អនុសញ្ញាស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថានឆ្លងដែន បង្ហាញគោលបំណងដែលមាន ការទទួលស្គាល់យ៉ាងច្បាស់ សម្រាប់ការវាយតម្លៃផលប៉ះពាល់បរិស្ថាន ដូចជាតម្រូវការដើម្បី:

១. "ពិចារណាយ៉ាងច្បាស់លាស់ចំពោះកត្តាបរិស្ថានតាំងពីដំណាក់កាលដំបូង ក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត ដោយអនុវត្ត ការវាយតម្លៃផលប៉ះពាល់បរិស្ថាន ដែលជាឧបករណ៍យ៉ាងចាំបាច់ ដើម្បីបង្កើនគុណភាពព័ត៌មាន ដែលដាក់ជូនទៅក្រុមអ្នកសម្រេចចិត្ត ដើម្បីឱ្យការសម្រេចចិត្តនេះមានលក្ខណៈទាក់ទងនឹងបរិស្ថាននេះ អាចត្រូវបានធ្វើឡើងយ៉ាងយកចិត្តទុកដាក់ ដើម្បីកាត់បន្ថយផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរនោះ ឱ្យនៅកម្រិតទាបបំផុត ជាពិសេសក្នុងស្ថានភាពនៃផលប៉ះពាល់ឆ្លងដែន",

២. "បង្កើត នីតិវិធីសម្រាប់វាយតម្លៃផលប៉ះពាល់បរិស្ថានដែលអនុញ្ញាតឱ្យមានការចូលរួម និងការរៀបចំឯកសារវាយតម្លៃផលប៉ះពាល់បរិស្ថានជាសាធារណៈ" និង

៣. អនុវត្ត ការវាយតម្លៃផលប៉ះពាល់បរិស្ថាន មុននឹងធ្វើសេចក្តីសម្រេចចិត្តអនុញ្ញាត ឬអនុវត្តសំណើគម្រោងទំនប់ធំ" ។[១០]

ការវាយតម្លៃផលប៉ះពាល់បរិស្ថានសម្រាប់ទំនប់សាយ៉ាប៊ូរី ខកខានមិនបានបំពេញគោលបំណងទាំងនេះទេ។ យ៉ាងហោចណាស់មានការពិនិត្យវាយតម្លៃ៤ដោយឡែកពីគ្នាលើការវាយតម្លៃផលប៉ះពាល់បរិស្ថាននេះ ដោយបានលើកមកពិភាក្សាអំពីចំណុចខ្វះខាតដែលបង្ហាញថា ផ្ទុយពីលក្ខខណ្ឌអន្តរជាតិសម្រាប់ការអភិវឌ្ឍទ្រង់ទ្រាយធំបែបនេះ។ ការពិនិត្យឡើងវិញលើគម្រោង ដោយលេខាធិការដ្ឋានគណៈកម្មាធិការទន្លេមេគង្គ ក៏បានលើកឡើងនូវក្តីបារម្ភយ៉ាងខ្លាំងអំពីផលប៉ះពាល់បរិស្ថានដោយសារគម្រោងនេះដែរ។

ការវាយតម្លៃយ៉ាងល្អិតល្អន់មួយត្រូវបានធ្វើឡើងដោយអ្នកវិទ្យាសាស្ត្រ និងអ្នកជំនាញផ្នែកទំនប់ នៅក្នុងការពិនិត្យយ៉ាងល្អិតល្អន់របស់ពួកគាត់ លើផ្នែកជម្រកត្រី ដែលជាការសិក្សាលទ្ធភាពរបស់គម្រោង និងការវាយតម្លៃផលប៉ះពាល់បរិស្ថានដោយផ្តោតជាពិសេសលើជណ្តើរសម្រាប់ត្រី ដែលស្នើឡើងជាវិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថាន។ ជាពិសេស បទដ្ឋានសម្រាប់ការពិនិត្យឡើងវិញនេះ ឆ្លើយតបនឹងគោលការណ៍ណែនាំរបស់ធនាគារអភិវឌ្ឍន៍អាស៊ី សមាគមអន្តរជាតិដើម្បីការវាយតម្លៃផលប៉ះពាល់ សមាគមវារីអគ្គិសនីអន្តរជាតិ និងគណៈកម្មការទំនប់វារីអគ្គិសនីពិភពលោក។[១១] ក្រុមអ្នកវិទ្យាសាស្ត្រ និងជំនាញការទាំងនោះ បានសន្និដ្ឋានការវាយតម្លៃរបស់ពួកគាត់ដូចខាងក្រោមៈ

ការខ្វះចន្លោះក្នុងការវាយតម្លៃនេះជាលទ្ធផលនាំឱ្យមានការសន្និដ្ឋានថា ការវាយតម្លៃផលប៉ះពាល់បរិស្ថានមិនបានបំពេញបទដ្ឋានអន្តរជាតិសម្រាប់ការវាយតម្លៃផលប៉ះពាល់បរិស្ថានទេ។ ការវាយតម្លៃផលប៉ះពាល់

បរិស្ថាននៃទំនប់សាយ៉ាប៊ូរី មិនឆ្លើយតបនឹងសំណួរអំពី លក្ខណៈ ទំហំ និងកម្រិតនៃផលប៉ះពាល់ដែលអាចកើតឡើងដោយសារគម្រោងដែលស្នើឡើងនោះទេ ឬបញ្ចប់ទៅដោយគ្មានភស្តុតាងថា ផលប៉ះពាល់ទាំងនេះមិនសំខាន់នោះឡើយ។

ជាលទ្ធផល ក៏បានដាក់ចេញអនុសាសន៍ឱ្យធ្វើការពិនិត្យឡើងវិញលើ ការវាយតម្លៃផលប៉ះពាល់បរិស្ថានដោយសារគម្រោងនោះ ដើម្បីធ្វើយ៉ាងណាឱ្យមានការវាយតម្លៃផលប៉ះពាល់ឆ្លងដែន និងឆ្លើយតបនឹងបញ្ហាពាក់ព័ន្ធនឹង ផលប៉ះពាល់ និងវិធានការកាត់បន្ថយផលប៉ះពាល់ស្របទៅតាមវិធីអនុវត្តល្អបំផុតរបស់អន្តរជាតិ។ លើសពីការវាយតម្លៃផលប៉ះពាល់បរិស្ថាននេះទៅទៀត ត្រូវមានការវាយតម្លៃអំពីផលប៉ះពាល់កើនឡើង ដោយយកចិត្តទុកដាក់លើផលប៉ះពាល់ដែលអាចនឹងកើតមានដោយសារទំនប់សាយ៉ាប៊ូរី បន្ថែមលើផលប៉ះពាល់ដោយសារទំនប់ចំនួន៤៧ ផ្សេងទៀត ដែលអាចនឹងមាននៅក្នុងអាងទន្លេមេគង្គ នៅឆ្នាំ២០១៥។

...

ជាទូទៅ សំណើសំណង់ជណ្តើរសម្រាប់ត្រី ដែលបានស្នើឡើងដើម្បីកាត់បន្ថយផលប៉ះពាល់ដោយសារគម្រោងទំនប់សាយ៉ាប៊ូរី ពាក់ព័ន្ធនឹងការផ្លាស់ទីរបស់ត្រីនេះ បំពេញលក្ខខណ្ឌបានតែ៤ចំណុចទេ ក្នុងចំណោម៣០ចំណុច នៃគោលការណ៍ណែនាំរបស់គណៈកម្មការទន្លេមេគង្គគឺៈ *"គោលការណ៍ណែនាំអំពី ការរៀបចំ និងបង្កើតគម្រោង ជំហានដំបូង សម្រាប់សំណើសុំសាងសង់ទំនប់ទន្លេមេនៅក្នុងអាងទន្លេមេគង្គក្រោម"*, ប៉ុន្តែពុំបានបំពេញ ឬបង្ហាញភស្តុតាងថា បានបំពេញលក្ខខណ្ឌ១៩ចំណុចក្នុងចំណោមលក្ខខណ្ឌទាំង៣០ចំណុចនោះទេ។ សំណង់ជណ្តើរសម្រាប់ត្រី មិនបានយកការសាកល្បងមកធ្វើជាមូលដ្ឋានទេ លក្ខណៈខ្លះនៃសំណង់នេះពុំត្រូវបានរៀបរាប់លម្អិតទេ ចំណែកឯលក្ខណៈរបស់វាជាច្រើនទៀត មិនត្រូវតាមលក្ខណៈ ជីវសាស្ត្រពូជត្រីទន្លេមេគង្គទេ។[១២]

សាស្ត្រាចារ្យ ឡាន់ហ្សា មកពីសកលវិទ្យាល័យម៉ាសាឈូសិត មហាវិទ្យាល័យអាំហឺសថ៍ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ សហរដ្ឋអាមេរិក ក៏បានធ្វើសេចក្តីសន្និដ្ឋានច្បាស់ដូចគ្នានេះដែរថា "ការវាយតម្លៃផលប៉ះពាល់បរិស្ថាននេះបង្ហាញ ឱ្យឃើញថា ខ្វះភាពច្បាស់លាស់ ព្រោះវាមានសេចក្តីបញ្ជាក់មិនស្រប ឬមិនស៊ីចង្វាក់គ្នាជាច្រើន ហើយតាមទស្សនៈបច្ចេកទេស ការវាយតម្លៃនេះមិនអាចទទួលយកបានទេ", "ការវាយតម្លៃផលប៉ះពាល់បរិស្ថាននេះគឺពិតជាមានគុណភាពអន់បែបនេះ ដែលមើលទៅវាមិនអាចឆ្លើយតបនឹងអ្វីដែលថា ជាការផ្តល់ការគាំទ្រ ដល់សំណើសុំសាងសង់ទំនប់ទី១នៅលើទន្លេមេនៃទន្លេមេគង្គក្រោមនៅឡើយ", ការវាយតម្លៃផលប៉ះពាល់បរិស្ថាននេះមិនគ្រប់ជ្រុងជ្រោយ

ទេ ព្រមទាំងកែសម្រួលផលប៉ះពាល់លើធនធានជីវសាស្ត្រដោយសារទំនប់នេះច្រើនហួសហេតុ ដូចជាផលប៉ះពាល់លើគុណភាពទឹក ជីវសាស្ត្រទឹក ជម្រកត្រី និងសុខភាពសាធារណៈជាដើម។ ការវាយតម្លៃផលប៉ះពាល់បរិស្ថានដែលមានតម្លៃសម្រាប់ព័ត៌មានសំខាន់ៗ មិនត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍ទេ ចំណែកឯបញ្ហាបរិស្ថានធំៗក៏មិនត្រូវបានដោះស្រាយដែរ", និងថា "ការវាយតម្លៃផលប៉ះពាល់បរិស្ថានមិនបង្ហាញអំពីការយល់ដឹងថា តើទន្លេមានមុខនាទីយ៉ាងដូចម្តេចនោះទេ ថែមទាំងមិនបានផ្តោតលើបរិមាណទឹកហូរ ជាទំហំតែមួយនៃជីវសាស្ត្រទន្លេមេគង្គទេ"។[១៣] និយាយឱ្យចំទៅ វេជ្ជ: ហូហ្គាន់ មកពី មហាវិទ្យាល័យរ៉េណូ នៃសកលវិទ្យាល័យនេវ៉ាដា សហរដ្ឋអាមេរិក បានលើកឡើងថា ការវាយតម្លៃផលប៉ះពាល់បរិស្ថាននោះពិតជា "ខ្វះខាតទាំងស្រុង"[១៤] ចំណែកឯលោកប្លេកដែលជា បណ្ឌិតបេក្ខភាពវិញ បានធ្វើសេចក្តីសន្និដ្ឋានថា "ការវាយតម្លៃផលប៉ះពាល់បរិស្ថាននេះ ពិតជាធ្វេសប្រហែសយ៉ាងច្រើន ចំពោះ កម្រិតនិងទំហំនៃផលប៉ះពាល់គ្រប់ផ្នែកទាំងអស់ ..."។[១៥]

នៅក្នុងរបាយការណ៍របស់ខ្លួនស្តីពីការពិនិត្យឡើងវិញលើគម្រោង លេខាធិការដ្ឋាននៃគណៈកម្មការទន្លេមេគង្គក៏បានសង្ខេបអំពីក្តីបារម្ភជាច្រើនពាក់ព័ន្ធនឹងគម្រោងនោះដែរ។ ជាឧទាហរណ៍ ក្រុមជំនាញការផ្នែកជលផលរបស់លេខាធិការដ្ឋាននេះ បានសន្និដ្ឋានថា "សំណើសាងសង់ជណ្តើរសម្រាប់ត្រីផ្លាស់ប្តូរទីទៅទន្លេលើ និងបង្កភាពងាយស្រួលសម្រាប់ ការផ្លាស់ប្តូរទីរបស់ត្រីធំនៅទន្លេក្រោម ក៏ដូចជា សម្រាប់កន្លែងត្រីពង និងកូនត្រី មិនអាចទៅរួចទេ"។ របាយការណ៍របស់គណៈកម្មការទន្លេមេគង្គនេះក៏បានបញ្ជាក់ដែរថា "ប្រភេទត្រីដែលមានប្រវែង វែងជាង១៥០ ស.ម. មាន លទ្ធភាពអាចធ្វើដំណើរឆ្លងទៅទន្លេលើដោយជោគជ័យនោះតិចណាស់ ដែលនេះបញ្ជាក់ថា ត្រីអណ្តែងយក្សទន្លេមេគង្គដែលធ្លាប់ធ្វើដំណើរចុះឡើងតាមលក្ខណៈធម្មជាតិ ពិតជាអាចស្លាប់ផុតពូជជាមិនខាន" និងថា "កង្វះការយល់ដឹងអំពី លក្ខណៈត្រីមួយចំនួនដែលធ្វើដំណើរផ្លាស់ទី លក្ខណៈជីវសាស្ត្ររបស់វា និងសមត្ថភាពធ្វើដំណើរឆ្លងទំនប់ និងអាងទឹក អាចនាំឱ្យមានភាពមិនច្បាស់លាស់មួយចំនួនអំពីកម្រិតនៃផលប៉ះពាល់ទីជម្រកត្រី និងជីវភាពរស់នៅដែលពាក់ព័ន្ធ ទាំងស្ថានភាពនៅក្នុងប្រទេស ទាំងស្ថានភាពអន្តរប្រទេស"។[១៦]

សេចក្តីសន្និដ្ឋានយ៉ាងត្រឹមត្រូវ ពីការវាយតម្លៃទាំងនេះគឺ ការវាយតម្លៃផលប៉ះពាល់បរិស្ថានដោយសារទំនប់សាយ៉ាប៊ូរី ជាការវាយតម្លៃមិនគ្រប់ជ្រុងជ្រោយ និងមានចំណុចខ្វះខាត ព្រមទាំងមិនបំពេញតាមលក្ខខណ្ឌបទដ្ឋានអន្តរជាតិ សម្រាប់ការវាយតម្លៃផលប៉ះពាល់បរិស្ថានពីគម្រោងអភិវឌ្ឍន៍ធំៗ ដែលអាចនឹងមានផលប៉ះពាល់ឆ្លងដែនមិនអាចផ្លាស់ប្តូរបាន និងគួរចាប់អារម្មណ៍។ ការវាយតម្លៃផលប៉ះពាល់បរិស្ថាន គប្បីត្រូវធ្វើឡើងវិញ ពីព្រោះតាមស្ថានភាពបច្ចុប្បន្ន វាមិនអាចបង្កើតបានជាមូលដ្ឋានដែលមានការចូលរួម ការពិគ្រោះយោបល់ជាសាធារណៈ

យ៉ាងពេញលេញ ឬមានការសម្រេចចិត្តសមហេតុផលឡើយ។ លើសពីនេះទៅទៀត យើងដឹងថា ដំណើរការនៃការសាងសង់ទំនប់នេះ បានចាប់ផ្តើមរួចហើយ ទោះបីជា ការវាយតម្លៃផលប៉ះពាល់បរិស្ថាននេះ នៅមិនទាន់គ្រប់ជ្រុងជ្រោយ និងមានចំណុចខ្វះខាតជាក៏ដោយ។ ការធ្វើបែបនេះពិតជាផ្ទុយទាំងស្រុងចំពោះលក្ខខណ្ឌនៃបទដ្ឋានអន្តរជាតិដែលតម្រូវថា ការវាយតម្លៃផលប៉ះពាល់បរិស្ថានត្រូវតែបំពេញឱ្យបានគ្រប់ជ្រុងជ្រោយ មុននឹងធ្វើសេចក្តីសម្រេចចិត្តផ្តល់សិទ្ធិអនុវត្ត គម្រោងណាមួយ។

**២. ដោយសារការវាយតម្លៃផលប៉ះពាល់បរិស្ថានមានចំណុចខ្វះខាត និងមិនបានបញ្ចេញជាសាធារណៈ មុនពេលដំណើរការចូលរួម និងការពិគ្រោះយោលបល់ជាសាធារណៈ ដូច្នេះដំណើរការទាំងនេះ ពិតជាត្រូវធ្វើឱ្យខូចការយ៉ាងធ្ងន់ធ្ងរ។ នៅពេលដែល ការវាយតម្លៃផលប៉ះពាល់បរិស្ថានត្រូវបានបញ្ចប់ ពេលនោះការវិភាគត្រូវបង្កើតបានជាមូលដ្ឋានសម្រាប់ការចូលរួម និងពិគ្រោះយោបល់ជាសាធារណៈយ៉ាងសមហេតុផលអំពីទំនប់នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងនៅប្រទេសទាំងបីផ្សេងទៀតដែលស្ថិតនៅតាមដងទន្លេមេគង្គក្រោម។**

នៅក្នុងលិខិតរបស់យើង ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១១ យើងបានពន្យល់ថា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ បានបញ្ចប់ដំណើរការនៃនីតិវិធីសម្រាប់ ការជូនដំណឹង ការពិគ្រោះយោបល់ និងការយល់ព្រមជាមុនមុនពេលកំណត់ ដោយពុំផ្តល់ឱកាសឱ្យប្រទេសជិតខាងបញ្ចប់ដំណើរការនោះយ៉ាងត្រឹមត្រូវឡើយ។ ការធ្វើបែបនេះបានរំលោភបំពានកិច្ចព្រមព្រៀងគណៈកម្មការទន្លេមេគង្គ ព្រមទាំងខុសលក្ខខណ្ឌបទដ្ឋានយ៉ាងរឹងមាំរបស់សហគមន៍អន្តរជាតិ ដែលកំណត់ថា ត្រូវផ្សព្វផ្សាយព័ត៌មានអំពីផលប៉ះពាល់ធ្ងន់ធ្ងរដោយសារគម្រោងអភិវឌ្ឍន៍ទៅបណ្តាភាគីពាក់ព័ន្ធដែលប្រឈមផលប៉ះពាល់ រួមទាំងរដ្ឋាភិបាលនៃប្រទេសជិតខាង និងត្រូវផ្តល់ឱកាសយ៉ាងសមរម្យទៅភាគីពាក់ព័ន្ធទាំងនោះ ដើម្បីបានផ្តល់គំនិតត្រឡប់មកវិញយ៉ាងច្បាស់លាស់អំពីការសម្រេចចិត្តនោះ។

ដូចមានពន្យល់នៅក្នុងធម្មនុញ្ញពិភពលោកដើម្បីធម្មជាតិរបស់អង្គការសហប្រជាជាតិថា "ការធ្វើផែនការទាំងអស់ ត្រូវតែបញ្ចូលព័ត៌មានស្តីពី ការវាយតម្លៃផលប៉ះពាល់ធម្មជាតិ ដោយសារសំណើគោលនយោបាយ និងសកម្មភាពនានា, គ្រប់ផ្នែកទាំងអស់ត្រូវប្រកាសជាសាធារណៈ ទៅតាមមធ្យោបាយសមស្រប ឱ្យបានទាន់ពេលវេលា ដើម្បីទុកឱកាសឱ្យមានការពិគ្រោះយោបល់ និងការចូលរួមប្រកបដោយប្រសិទ្ធភាព"។[១៧] ហេតុដូច្នេះតាមលក្ខខណ្ឌអន្តរជាតិ ការសម្រេចចិត្តណាមួយរបស់រដ្ឋាភិបាលដែលធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់បរិស្ថាន រដ្ឋាភិបាលនោះត្រូវតែបង្ហាញអំពី ផលប៉ះពាល់នោះឱ្យបានលឿនបំផុតទៅសាធារណជន និងប្រទេសជិតខាង ដើម្បីសម្រួលដល់

ការចូលរួម និងការពិគ្រោះយោបល់ ដោយស្មោះត្រង់ យ៉ាងសមហេតុផល និងមានប្រសិទ្ធភាព ថា តើគម្រោងនោះមានពាក់ព័ន្ធអ្វីខ្លះ តើប្រជាពលរដ្ឋនៅក្នុងប្រទេស និងនៅប្រទេសជិតខាងទទួលរងផលប៉ះពាល់អ្វីខ្លះ តើគម្រោងនេះត្រូវបន្តដំណើរការឬទេ និងប្រសិនបើ ត្រូវបន្តដំណើរការ តើមានវិធានអ្វីខ្លះដើម្បីកាត់បន្ថយប៉ះពាល់យ៉ាងធ្ងន់ធ្ងរនោះ។[១៨] ការចូលរួម និងការពិគ្រោះ យោបល់នោះត្រូវតែផ្តោតលើកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការធានាឱ្យមានការចូលរួមពីប្រជាពលរដ្ឋដែលតែងតែជាមនុស្សដែលទន់ខ្សោយ និងត្រូវគេរើសអើងផ្នែកនយោបាយ ដូចជាស្ត្រីជាដើម។[១៩]

ការចូលរួមក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងបរិស្ថានត្រូវតែដឹង និងឆ្លុះបញ្ចាំងអំពីស្ថានភាព និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។ រហូតមកដល់ពេលនេះ គណៈកម្មការទន្លេមេគង្គ បានពន្យល់ថា ការចូលរួមជាសាធារណៈ នៅក្នុងស្ថានភាពនៃការងាររបស់គណៈកម្មការទន្លេមេគង្គ នៅក្នុងប្រទេសទាំងបួនដែលស្ថិតនៅតាមទន្លេមេគង្គក្រោម គឺជា "ដំណើរការមួយដែលភាគីពាក់ព័ន្ធ មានឥទ្ធិពល និងចូលរួមក្នុងការសម្រេចចិត្ត ក្នុងការធ្វើផែនការ អនុវត្តន៍ ពិនិត្យតាមដាននិងវាយតម្លៃ អំពីកម្មវិធី និងគម្រោងរបស់គណៈកម្មការទន្លេមេគង្គ"។[២០] ភាគីពាក់ព័ន្ធសំខាន់ៗគឺជា "អ្នកដែលអាចប្រើឥទ្ធិពលយ៉ាងខ្លាំង ឬអ្នកដែលសំខាន់ចំពោះជោគជ័យរបស់កម្មវិធី ឬគម្រោង"។ ភាគីទាំងនេះ អាចជា ប្រជាពលរដ្ឋដែលប្រឈមផលប៉ះពាល់ដោយផ្ទាល់ ប្រជាពលរដ្ឋដែលប្រឈមផលប៉ះពាល់ដោយប្រយោល ស្ថាប័នធារណៈ ក្រុមហ៊ុនអភិវឌ្ឍន៍ឯកជន អ្នកផ្តល់ជំនួយ អង្គការមិនមែនរដ្ឋាភិបាល ទីប្រឹក្សាពីខាងក្រៅ និងក្រុមហ៊ុននានា។[២១]

ដំណើរការចូលរួម និងពិគ្រោះយោបល់ជាសាធារណៈ របស់សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវសម្រាប់ទំនប់សាយ៉ាប៊ូរី មិនមានការចូលរួមយ៉ាងពេញលេញពីភាគីពាក់ព័ន្ធសំខាន់ៗក្នុងការវាយតម្លៃដោយចំហអំពីផលប៉ះពាល់ដោយសារទំនប់នេះទេ។ ឧទាហរណ៍ ការវាយតម្លៃផលប៉ះពាល់បរិស្ថាន (ដែលមានចំណុចខ្វះខាតនោះ) មិនត្រូវបានរៀបចំ និងសរសេរជាភាសាឡាវទេ ឬនៅពេលនោះ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ បានអនុវត្តកិច្ចការពិគ្រោះយោបល់ជាច្រើនជាមួយភាគីពាក់ព័ន្ធសំខាន់ៗក្នុងដែនសមត្ថកិច្ចរបស់ខ្លួនតែប៉ុណ្ណោះ។[២២] ដូច្នេះវាមិនច្បាស់ទេថា តើផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារគម្រោងអ្វីខ្លះត្រូវបានបង្ហាញឱ្យភាគីពាក់ព័ន្ធទាំងនេះដឹង ព្រោះថា ផលប៉ះពាល់បែបនោះ នៅមិនទាន់ត្រូវបានរៀបចំជាឯកសារ និងត្រូវបានវាយតម្លៃយ៉ាងពេញលេញនៅក្នុងការវាយតម្លៃផលប៉ះពាល់បរិស្ថាននោះ នៅឡើយ។ ការពិគ្រោះយោបល់ជាបន្តបន្ទាប់នេះ អាចនឹងធ្វើឱ្យខូចការដល់លទ្ធភាពរបស់ប្រជាពលរដ្ឋដែលប្រឈមផលប៉ះពាល់ក្នុងការចូលរួម និងដើម្បីពិគ្រោះយោបល់អំពី សំណើ

គម្រោងដែលបានរៀបចំ និងលទ្ធភាពជម្រើសផ្សេងៗ, ផលប៉ះពាល់សង្គមនិងបរិស្ថានដែលអាចនឹងកើតមាន ចំពោះប្រជាពលរដ្ឋនៅមូលដ្ឋាន និងសំណើវិធានការមួយចំនួនដើម្បី កាត់បន្ថយផលប៉ះពាល់នោះ។ គេមិនរំពឹងថា ប្រជាពលរដ្ឋ អាចចូលរួមផ្តល់យោបល់ច្បាស់លាស់ ឬធ្វើសេចក្តីសម្រេចចិត្តច្បាស់លាស់ អំពីផលប៉ះពាល់ធំៗដល់ ការរស់នៅរបស់ប្រជាពលរដ្ឋ ដោយសារគម្រោងអភិវឌ្ឍន៍នោះទេ ប្រសិនបើ ពួកគាត់គ្មានឯកសារជាភាសារបស់គាត់ ដើម្បីឱ្យពួកគាត់យល់អំពីផលប៉ះពាល់ទាំងនេះ និងថា ត្រូវកាត់បន្ថយផលប៉ះពាល់ទាំងនេះដោយវិធីណាទេ។

ថ្វីត្បិតថា ការវាយតម្លៃផលប៉ះពាល់បរិស្ថានត្រូវលើកមកពិភាក្សាជាក់ស្តែងចំនួន៣លើក នៅសាធារណរដ្ឋ ប្រជាធិបតេយ្យប្រជាមានិតឡាវនៅក្នុងខែសីហា ឆ្នាំ២០១០ ក៏ដោយ ក៏ការពិភាក្សានោះបង្ហាញថា ក្នុងការប្រជុំ ទាំងបីលើកនោះ មានតែការប្រជុំមួយលើកទេ ដែលមានតំណាងអ្នកភូមិដែលប្រឈមផលប៉ះពាល់បានចូលរួម និង ដោយសារ ការវាយតម្លៃផលប៉ះពាល់បរិស្ថាននោះបង្ហាញឱ្យឃើញនូវការវិភាគអំពីផលប៉ះពាល់ពីគម្រោង មិនគ្រប់ ជ្រុងជ្រោយ ដូច្នេះការពិគ្រោះយោបល់ដែលយកឯកសារនេះធ្វើជាមូលដ្ឋាន មិនអាចចាត់ទុកថា គ្រប់គ្រាន់ទេ។[២៣] យើងក៏បានដឹងដែរថា ឯកសារសម្រាប់ការសម្រេចចិត្តយ៉ាងសំខាន់ៗសម្រាប់ទំនប់សាយ៉ាប៊ូរី ដូចជារបាយការណ៍ស្តីពី ការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងឯកសារវាយតម្លៃស្តីពីផលប៉ះពាល់សង្គម មិនបានប្រកាសជាសាធារណៈ ឬចែក ចាយជូន ប្រជាពលរដ្ឋដែលប្រឈមនឹងផលប៉ះពាល់ទាំងនេះបានដឹងមុនពេល បើកការពិគ្រោះយោបល់នៅមូលដ្ឋាន ទាំងនោះទេ។[២៤] លើសពីនេះទៅទៀត វាហាក់ដូចជាបង្ហាញឱ្យឃើញថា អ្នកដែលចុះស្រង់មតិពីប្រជាពលរដ្ឋដែល រស់នៅតាមភូមិដែលប្រឈមផលប៉ះពាល់ដោយសារគម្រោងទំនប់នេះ ពិតជាគ្មានចេតនាចុះស្រង់មតិ ឬជួបពិគ្រោះ យោបល់ជាមួយស្ត្រីទេ ផ្ទុយទៅវិញ ពួកគាត់យកចិត្តទុកដាក់ ចុះសម្ភាសជាមួយបុរសតែប៉ុណ្ណោះ។[២៥]

ចំពោះចំណុចពាក់ព័ន្ធដូចគ្នានេះដែរ ដោយសារការវាយតម្លៃប៉ះពាល់បរិស្ថានមានចំណុចខ្វះខាត ដូច្នេះឯកសារ នោះខកខានមិនបានផ្តល់មូលដ្ឋានតាមផ្លូវច្បាប់ សម្រាប់ការពិគ្រោះយោបល់ទាំងនោះ និងការពាក់ព័ន្ធជាមួយភាគី ពាក់ព័ន្ធសំខាន់ៗផ្សេងទៀតឡើយ រួមទាំងថ្នាក់ដឹកនាំរបស់ប្រទេសជិតខាង ដូចជា កម្ពុជា ថៃ និងវៀតណាម។ ការខកខាន បែបនេះ ធ្វើឱ្យគុណប្រយោជន៍របស់ព័ត៌មានដែលបានចែករំលែក និងការពិគ្រោះយោបល់ដែលមិនបាន ប្រព្រឹត្តទៅនៅក្នុងប្រទេសទាំងនោះ កាន់តែលែងមានតម្លៃបន្ថែមទៀត។

## ៣. ការសម្រេចចិត្តអនុម័តគម្រោងទំនប់សាយ៉ាប៊ូរី តាមការស្នើសុំ នឹងបណ្តាលឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ប្រព័ន្ធជីវសិរីរាង្គចម្រុះដែលប្រើរួមគ្នាដោយប្រទេសផ្សេងៗទៀត និងធ្វើឱ្យសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រព្រឹត្តផ្ទុយពីកាតព្វកិច្ចរបស់ខ្លួនតាមអនុសញ្ញាស្តីពីប្រព័ន្ធជីវសិរីរាង្គចម្រុះ ។

ទន្លេមេគង្គជាទន្លេមួយក្នុងចំណោមទន្លេនានានៅក្នុងពិភពលោក ដែលមានប្រព័ន្ធជីវសិរីរាង្គចម្រុះ និងមានផលិតភាពច្រើនបំផុត ។ វាជាតំបន់សម្បូរត្រីទឹកសាបនៅក្នុងពិភពលោក ព្រោះមានពូជត្រីជាង១000ប្រភេទ នៅក្នុងទន្លេនេះ ត្រូវបានគេកត់ត្រាទុក (ចាញ់តែទន្លេអាមេហ្សូនមួយប៉ុណ្ណោះ) ។ ក្នុងចំណោមប្រព័ន្ធជីវសិរីរាង្គចម្រុះនេះ ទន្លេមេគង្គជាទីជម្រកដែលមានពូជត្រី ទឹកសាបធំៗ ច្រើនជាងទន្លេផ្សេងៗទៀត រួមទាំងត្រីអណ្តែងយក្សទន្លេមេគង្គ[២៦], ត្រីប្រាយក្ស (*Pangasius sanitwongsei*), ត្រីចង្វាយក្ស (*Probarbus jullieni*), និងត្រីក្អែកយក្ស (*Catlocarpio siamensis*) ដែលសុទ្ធតែជាពូជត្រីកម្រ និងប្រឈមការបាត់បង់ផុតពូជ ។[២៧] ទន្លេមេគង្គក៏ជាអាងត្រីទឹកសាបធំបំផុត និងមានផលិតភាពច្រើន បំផុតនៅក្នុងពិភពលោក ដែលផ្តល់ទិន្នផលសរុបនៅរដូវនេសាទប្រហែល ២,៥លានតោនក្នុងមួយឆ្នាំ ដែលមានតម្លៃជា ប្រាក់ពី ៣.៦00.000.000,00 ទៅ៦.៥00.000.000,00 ដុល្លារក្នុងមួយឆ្នាំ និងមានទិន្នផលត្រីចល័តនៅរដូវ នេសាទ ប្រមាណពី៤0 ទៅ៧0ភាគរយ ។[២៨]

ការអភិរក្សប្រព័ន្ធជីវសិរីរាង្គចម្រុះ និងជម្រកត្រី មានសារសំខាន់បំផុតសម្រប់តំបន់និងពិភពលោក ។ អ្វីដែលគួរឱ្យបារម្ភនោះគឺ អ្នកជំនាញឯករាជបានធ្វើសេចក្តីសន្និដ្ឋានថា ទំនប់សាយ៉ាប៊ូរី ប្រសិនបើ ត្រូវបានសាងសង់តាមផែនការ នោះវានឹងបង្កឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រព័ន្ធជីវសិរីរាង្គចម្រុះនេះ និយាយឱ្យទូលំទូលាយជាងនេះគឺជម្រកត្រី ។ Baran et al បានសន្និដ្ឋានថា ដល់ឆ្នាំ២០១៥ "ពូជត្រីពនាចរ៩ប្រភេទក្នុងចំណោម៧0ប្រភេទដែលរស់នៅ ឬប្រើប្រាស់តំបន់ដែល មានផលប៉ះពាល់ដោយទំនប់ និងអាងទំនប់ទឹក នឹងត្រូវចាត់ចូលជាប្រភេទត្រីកម្រ និងបានសន្និដ្ឋានទៀតថា ការសាង សង់ទំនប់សាយ៉ាប៊ូរី ធ្វើឱ្យចំនួននេះកើនឡើងរហូត១៥" ព្រមទាំងថា ពូជត្រីអណ្តែងមួយប្រភេទទៀត នឹងត្រូវចូល ជាមួយពូជត្រីកម្រពីរប្រភេទទៀតគឺ *Pangasianodon gigas* និង *Pangasius sanitwongsei* ដោយសារតែ ការសាងសង់ទំនប់នេះ" ។[២៩]

លោក ហូហ្គានក៏បានធ្វើសេចក្តីសន្និដ្ឋានដូចគ្នានេះដែរថា "តាមភស្តុតាងដែលមានទាំងអស់ បានបង្ហាញថា ទំនប់សាយ៉ាប៊ូរីនឹងមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើ ត្រីពនាចរ និងត្រីជិតផុតពូជនៅក្នុងទន្លេមេគង្គក្រោម និងអាចធ្វើឱ្យពូជត្រីទឹកសាបធំបំផុតពីររបស់ទន្លេមេគង្គ គឺត្រីអណ្តែងយក្សទន្លេមេគង្គ និងត្រីប្រាយក្សឈានទៅស្លាប់ផុតពូជ ។[៣០]

ក្នុងការអនុម័តការសាងសង់ទំនប់សាយ៉ាប៊ូរីតាមការស្នើសុំនេះ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ មិនដឹងអំពីផលប៉ះពាល់ដែលអាចកើតមានចំពោះប្រព័ន្ធជីវសិរីរាង្គចម្រុះដោយសារគម្រោងនេះផង និងមានបំណងសាងសង់ទំនប់នេះ ដោយមិនគិតពីផលប៉ះពាល់ទាំងនេះឡើយ។ តាមទស្សនៈទាំងពីរនេះ ប្រាប់ថា ការសម្រេចចិត្តរបស់រដ្ឋាភិបាល ផ្ទុយពីលក្ខខណ្ឌអភិរក្ស និងស្តារនីតិសម្បទាពូជត្រី ទៅតាមអនុសញ្ញាស្តីពីប្រព័ន្ធជីវសិរីរាង្គចម្រុះ។ តាមអនុសញ្ញាអំពី ប្រព័ន្ធជីវសិរីរាង្គចម្រុះនេះ ផ្តល់និយមន័យនៃពាក្យប្រព័ន្ធជីវសិរីរាង្គចម្រុះថា "ស្ថានភាពប្រែប្រួលក្នុងចំណោមជីវសិរីរាង្គ ពីគ្រប់ប្រភពទាំងអស់ ដូចជា ប្រព័ន្ធសិរីរាង្គក្នុងទឹក និងបរិវេណប្រព័ន្ធសិរីរាង្គដែលជាផ្នែកនៃសិរីរាង្គ ដូចជា ភាពចម្រុះក្នុងចំណោមពូជត្រី រវាងពូជត្រីនិងប្រព័ន្ធជីវសិរីរាង្គ"។[៣១] ភាគីនីមួយៗនៃអនុសញ្ញាស្តីពីប្រព័ន្ធជីវសិរីរាង្គចម្រុះ បានអះអាងបញ្ជាក់ថា "រដ្ឋនីមួយៗត្រូវ ទទួលខុសត្រូវរក្សាធនធានជីវសាស្ត្រចម្រុះ និងប្រើប្រាស់ធនធានជីវសាស្ត្ររបស់ខ្លួនប្រកបដោយនិរន្តរភាព"។ តាមមាត្រា៣នៃអនុសញ្ញានេះបញ្ជាក់ថា គ្មានរដ្ឋហត្ថលេខីណាមួយ អាចបន្តការអភិវឌ្ឍនៅក្នុងទឹកដីរបស់ខ្លួនដែល ការអភិវឌ្ឍនោះបណ្តាលឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ប្រព័ន្ធជីវសិរីរាង្គចម្រុះនៅក្នុងរដ្ឋផ្សេងៗទៀតឡើយ។[៣២]

តាមការវាយតម្លៃរបស់អ្នកជំនាញការអំពីការវាយតម្លៃផលប៉ះពាល់បរិស្ថានទំនប់សាយ៉ាប៊ូរី បង្ហាញថា ការវាយតម្លៃផលប៉ះពាល់បរិស្ថាននោះ មិនបានវិភាគល្អិតល្អន់អំពីផលប៉ះពាល់ដែលអាចនឹងកើតឡើងដោយទំនប់នេះទៅលើប្រព័ន្ធជីវសិរីរាង្គចម្រុះ ឬលើការបាត់បង់ពូជត្រីទេ។ ការវាយតម្លៃនេះច្រើនពេកដែលមិនអាចនិយាយបានទាំងអស់ទេ ប៉ុន្តែក្តីបារម្ភយ៉ាងខ្លាំងមួយចំនួនដែលលទ្ធផលនៃការវាយតម្លៃរបស់ Baran et al មានសង្ខេបជូនដូចខាងក្រោមៈ

**<u>ចំពោះការវាយតម្លៃផលប៉ះពាល់បរិស្ថាន និយាយជាទូទៅៈ</u>**

- "រយៈពេលបំពេញអាងទឹក (ដែលអូសបន្លាយពេលជាច្រើនឆ្នាំ), កម្រិតនៃការរក្សាទឹកនៅខាងក្រោយទំនប់ ... និងផលប៉ះពាល់លើកម្រិតទឹកហូរយឺតនៅរដូវប្រាំងនៅទន្លេមេ ... មិនត្រូវបានសរសេរលម្អិត និង មិនត្រូវបានលើកមកពិភាក្សានៅក្នុងរបាយការណ៍ស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថានទេ ទោះបីជា ទាំងអស់នេះជាកត្តាដែលអាចរំខានដល់ធនធានត្រីក្នុងស្រុក ការចល័តឆ្លងដែន និងជម្រកត្រីនៅទន្លេក្រោម ក៏ដោយ"។[៣៣]
- "ដំណាំចំនួន២០០០ហិកតារ ពិតជានឹងត្រូវលិចទឹកដោយសារអាងទំនប់ទឹកនោះ ព្រមទាំងត្រូវស្ទុយរលួយក្នុងរយៈពេលជាច្រើនឆ្នាំខាងមុខនេះ។ នៅក្នុងរបាយការណ៍ស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន ផ្នែកដែលបានសិក្សានោះ មានកម្រិតណាស់ចំពោះតំបន់ទំនប់នោះ គឺសិក្សាបានតែ២១ហិកតារតែប៉ុណ្ណោះ។ នេះបង្ហាញ

ឱ្យឃើញអំពី ការវាយតម្លៃមិនគ្រប់ជ្រុងជ្រោយរហូតដល់១០០ដងនៃតំបន់ទន្លេលើដែលទទួលរងផលប៉ះពាល់ និងចំណុចខ្វះខាតដែលពាក់ព័ន្ធនឹងផលប៉ះពាល់ដោយសារគម្រោងទៅលើគុណភាពទឹកទន្លេក្រោម។ ជាការពិតណាស់ ផលប៉ះពាល់ដែលអាចកើតឡើងដោយសារដំណាំស្អុយរលួយនៅក្នុងអាងទំនប់នោះ មិនត្រូវបានលើកមកនិយាយនៅក្នុងរបាយការណ៍ ២សន្លឹកដែលផ្តោតលើគុណភាពទឹកទន្លេក្រោមនោះទេ"។[៣៤]

- "នៅក្នុងរបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថានដោយសារទំនប់សាយ៉ាបួរី ការបង្កើតឱ្យមានផែនទឹកជាអចិន្ត្រៃយ៍ត្រូវបំភ្លេច ព្រមទាំងមិនបានលើកឡើងអំពីផលវិបាកចំពោះធនធានជម្រកត្រី ដែលផ្លាស់ប្តូរទឹកហូរប្រវែងយ៉ាងតិច៦០គ.ម. ទៅជាទឹកបឹង"។[៣៥]
- "ការវាយតម្លៃផលប៉ះពាល់បរិស្ថានដោយសារទំនប់សាយ៉ាបួរី មិនបានលើកឡើងអំពីស្ថានភាពផលប៉ះពាល់ឆ្លងដែនដែលអាចនឹងកើតមាននោះទេ"។[៣៦]
- "ការរៀបរាប់អំពីការផ្លាស់ទីរបស់ត្រីទន្លេមេគង្គ នៅក្នុងរបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាននោះពិតជាអន់ណាស់ ដែលការពិនិត្យលើខ្លឹមសាររបាយការណ៍នោះឃើញមានប្រភពយោងតែបីប៉ុណ្ណោះ ចំណែកឯការសិក្សាផ្សេងទៀតបានរកឃើញ ជាង២៨នៃរបាយការណ៍សិក្សា និងប្រភពព័ត៌មានស្តីពីការផ្លាស់ទីរបស់ត្រីទន្លេមេគង្គ ដែលទាំងអស់នេះសុទ្ធតែអាចយកមកប្រើប្រាស់បាននៅក្នុងអំឡុងពេលនៃដំណើរការនៃការវាយតម្លៃផលប៉ះពាល់បរិស្ថាន។ ជាលទ្ធផល របាយការណ៍ស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន មិនបានទាញសេចក្តីសន្និដ្ឋានអំពីសារសំខាន់នៃការផ្លាស់ទីរបស់ត្រីទន្លេមេគង្គ នៅក្នុងផ្នែកអំពីផលប៉ះពាល់ដោយសារគម្រោងនោះទេ។[៣៧]
- តាមការស្រាវជ្រាវបន្តដោយផ្អែកលើការពិនិត្យលើទិន្នន័យជាង៧០អត្ថបទផ្សេងៗ និងបញ្ជីពូជត្រីជាច្រើននោះ បានបង្ហាញឱ្យឃើញថា ពូជត្រី២២៩ប្រភេទ រស់នៅក្នុងទន្លេលើនៃតំបន់ទំនប់ដែលគ្រោងសាងសង់ដើម្បីពង និងជ្រកកោននៅរដូវប្រាំង ក្នុងចំណោមពូជត្រីទាំង២២៩នេះ មាន៧០ប្រភេទជាពូជត្រីពនាចរ។ ក្នុងចំណោមពូជត្រីទាំងនោះ មានខ្លះជាពូជត្រីកម្រមាន និងកំពុងប្រឈមការងាប់ផុតពូជ ដូចជា ត្រីអណ្តែងយក្សទន្លេមេគង្គជាដើម។ ផ្ទុយទៅវិញ របាយការណ៍ស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន បានលើកឡើងអំពីពូជត្រីពីក្នុងបញ្ជីចាស់ដែលមានតែ១៦ប្រភេទតែប៉ុណ្ណោះ ដែលក្នុងចំណោម១៦ប្រភេទនោះមានពូជត្រីពនាចរចំនួន៥ប្រភេទ។[៣៨]

**<u>ចំពោះសំណើសាងសង់ជណ្ដើរសម្រាប់ត្រី និយាយដោយខ្សែក៖</u>**

- "និយមន័យអំពីពូជត្រីដែលជាគោលដៅមួយចំនួន គ្មាននៅក្នុងផ្នែកស្ដីពីការកាត់បន្ថយផលប៉ះពាល់ធ្ងន់ធ្ងរ នៃការវាយតម្លៃផលប៉ះពាល់បរិស្ថានទេ ដែលជាលទ្ធផលនាំឱ្យមានការជ្រើសរើសគំរូជណ្ដើរសម្រាប់ត្រី គ្មានមូលដ្ឋានច្បាស់លាស់ទេ" ។[៣៩]
- "សូម្បីតែប្លង់លម្អិត ឬគំនូរអំពីជណ្ដើរសម្រាប់ត្រី ក៏គ្មាននៅក្នុងរបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថានដែរ ដែលធ្វើឱ្យសំណើសុំនោះមិនច្បាស់លាស់" ។[៤០]
- "សំណើសំណង់ជណ្ដើរសម្រាប់ត្រីនោះ មិនបានយោងទៅបទពិសោធន៍ពាក់ព័ន្ធណាមួយ នៅក្នុងពិភពលោកនោះទេ និងសូម្បីតែយោងទៅឯកសារ ឬសៀវភៅដែលជាប្រភពដើម្បីបញ្ជាក់ហេតុផលក៏គ្មានដែរ" ។[៤១]
- "របាយការណ៍ស្ដីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន មិនបានបញ្ជាក់ហេតុផលអំពីលក្ខណៈនៃការរៀបចំជណ្ដើរសម្រាប់ត្រី ក្នុងស្ថានភាពហែលឡើងទេ" ។[៤២]
- "របាយការណ៍ស្ដីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាននោះ មិនបានបញ្ជាក់ច្បាស់លាស់ថា តើត្រីពនាចរនឹងត្រូវប្រឈមផលប៉ះពាល់ នៅក្នុងអំឡុងពេលសាងសង [រយៈពេលប្រាំបីឆ្នាំ] នោះយ៉ាងណានោះទេ ព្រមទាំងមិនបានកំណត់ច្បាស់លាស់អំពីវិធានការកាត់បន្ថយផលប៉ះពាល់ណាមួយនៅក្នុងអំឡុងពេលនោះទេ" ។[៤៣]
- អ្នកនិពន្ធម្នាក់ទៀត គឺលោកវេជ្ជ. ហូហ្គាន់ បានធ្វើសេចក្ដីសន្និដ្ឋានថា ត្រីមួយក្រុមក្នុងចំណោមត្រីសំខាន់ៗបំផុត ដែលរស់នៅតាមតំបន់សាយ៉ាប៊ូរី (និងទន្លេមេគង្គទាំងមូល) គឺត្រីប្រាយក្សដែល "អាចមានសមត្ថភាពផ្លាស់ប្ដូរទី រវាងតំបន់ដីសណ្ដទន្លេមេគង្គ និងតំបន់សាយ៉ាប៊ូរី មានន័យថា ផលប៉ះពាល់ដោយសារទំនប់សាយ៉ាប៊ូរី អាចគ្របដណ្ដប់លើផ្ទៃដីធំណាស់គឺ ពីភាគខាងជើងទៅដល់ភាគឦសាននៃប្រទេសថៃ ទៅដល់ភាគខាងត្បូងនៃប្រទេសឡាវ កម្ពុជា និងប្រទេសវៀតណាម" ប៉ុន្តែ "របាយការណ៍ស្ដីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន មិនបានគិតអំពីផលប៉ះពាល់ឆ្លងដែនទេ" ។[៤៤]

ចំណុចគួរឱ្យកត់សម្គាល់យ៉ាងខ្លាំងទាំងនេះ បង្ហាញថា របាយការណ៍ស្ដីពីការវាយតម្លៃផលប៉ះពាល់បរិស្ថានដោយសារទំនប់សាយ៉ាប៊ូរី ខកខានមិនបានធ្វើការវិភាគយ៉ាងល្អិតល្អន់អំពីផលប៉ះពាល់លើជម្រកត្រីទេ ទោះបីជាថាទន្លេមេគង្គ ជាជម្រកត្រីធំបំផុតនៅក្នុងពិភពលោក និងគ្រោះថ្នាក់ចំពោះជម្រកត្រីដោយសារទំនប់នេះ (ដែលជាគម្រោងទី១ ក្នុងចំណោម គម្រោងទាំង៧សម្រាប់ទន្លេមេនៃទន្លេមេគង្គក្រោម) អាចធ្វើឱ្យមានការព្រួយបារម្ភ

យ៉ាងខ្លាំងបំផុតក៏ដោយ។ ដោយសារតែ របាយការណ៍ស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន មានលក្ខណៈមិនពេញលេញ និងមិនគ្រប់ជ្រុងជ្រោយ និងដោយសារគ្មានផែនការគួរឱ្យទុកចិត្តណាមួយដែលថា ផលប៉ះពាល់ធ្ងន់ធ្ងរអាចត្រូវបានកាត់បន្ថយសមល្មម ដូចជាការសាងសង់ជណ្តើរសម្រាប់ត្រីសមរម្យជាដើមនោះ ដូច្នេះ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ គ្មានមូលដ្ឋានសមហេតុផលណាមួយដើម្បីអនុម័តគម្រោងដែលស្នើសុំនោះទេ។ ហេតុដូច្នេះ សេចក្តីសម្រេចចិត្តរបស់ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ទំនងជា "បណ្តាលឱ្យមានការខូចខាតដល់បរិស្ថានរបស់ប្រទេសផ្សេងៗ" ដែលផ្ទុយនឹងមាត្រា៣នៃអនុសញ្ញាស្តីពីប្រព័ន្ធជីវសរីរាង្គចម្រុះ។

ក្នុងសេចក្តីកត់សម្គាល់មួយទៀតដូចគ្នានេះដែរ តាមមាត្រា៧នៃអនុសញ្ញាស្តីពីប្រព័ន្ធជីវសរីរាង្គចម្រុះ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ក៏ "ត្រូវ" "(c) កំណត់ឱ្យបានច្បាស់ដែរ អំពីដំណើរការនិងប្រភេទនៃសកម្មភាពដែលមាន ឬដែលអាចនឹងមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើការអភិរក្ស និងការប្រើប្រាស់ប្រព័ន្ធជីវសរីរាង្គចម្រុះដោយនិរន្តរភាព ព្រមទាំងពិនិត្យតាមដាន អំពីឥទ្ធិពលរបស់វាដោយប្រើបច្ចេកទេសតាមគំរូណាមួយ និងបច្ចេកទេសផ្សេងៗទៀត"។ តាមមាត្រា៨ ចំណុច (f) នៃអនុសញ្ញាស្តីពីប្រព័ន្ធជីវសរីរាង្គចម្រុះ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ក៏ត្រូវស្តារឡើងវិញនូវប្រព័ន្ធជីវសរីរាង្គដែលមានស្ថានភាពមិនល្អ និងជំរុញឱ្យមានការស្តារឡើងវិញនូវពូជត្រីដែលកំពុងប្រឈមការគំរាមកំហែង ជាឧទាហរណ៍ តាមរយៈការរៀបចំនិងអនុវត្តផែនការ ឬយុទ្ធសាស្ត្រគ្រប់គ្រងផ្សេងៗទៀត"។ លក្ខខណ្ឌទាំងពីរនេះ បញ្ជាក់អំពី សារសំខាន់នៃការយល់ដឹង និងការរៀបចំឯកសារដូចជា ផលប៉ះពាល់កើនឡើងដោយសារ ទំនប់សាយ៉ាបួរី នៅពេលសង់វាបន្ថែមលើទំនប់ទាំងអស់ដែលកំពុងអនុវត្ត និងបានស្នើសុំសាងសង់នៅតាមដងទន្លេមេគង្គ។

Baran et al ពន្យល់ថា "រហូតឆ្នាំ២០១៨ ប្រសិនបើទំនប់សាយ៉ាបួរីត្រូវបានសាងសង់ នោះវានឹងក្លាយជាទំនប់មួយ ក្នុងចំណោមទំនប់ចំនួន៤៨នៅក្នុងអាងទន្លេមេគង្គ និងជាទំនប់ធំបំផុតនៅក្នុងអាងទន្លេមេគង្គក្រោម"។ អ្នកនិពន្ធរូបនោះបានចង្អុលបង្ហាញថា "នៅប្រទេសសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ គម្រោងទំនប់ណាំធឿន២ (១.០៧៥ MW) ក៏ដូចជាគម្រោងទំនប់ណាំធឿន៣ (៤៤០ MW) ដែរនោះ ថ្មីៗនេះកំពុងស្ថិតក្រោមការវាយតម្លៃផលប៉ះពាល់កើនឡើង។ ប៉ុន្តែ របាយការណ៍ស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថានដែលត្រូវពិនិត្យឡើងវិញនោះ មិនបានលើកឡើងអំពីផលប៉ះពាល់កើនឡើងដោយសារ គម្រោងទំនប់សាយ៉ាបួរី ដែលមានកម្លាំង ១.២៦០ MW នោះទេ"។[៤៥] និយាយម្យ៉ាងទៀត ការវាយតម្លៃផលប៉ះពាល់កើនឡើង ត្រូវបានអនុវត្តចំពោះ តែទំនប់តូចៗ (ដែលតាមការសន្និដ្ឋាន មានផលប៉ះពាល់តិចតួច) តែប៉ុណ្ណោះ ប៉ុន្តែផ្ទុយទៅវិញ គ្មានការវាយតម្លៃ

ផលប៉ះពាល់កើនឡើងណាមួយ ត្រូវបានអនុវត្តចំពោះទំនប់សាយ៉ាបួរីមានទ្រង់ទ្រាយធំជាងឡើយ។ យើងក៏មិនបានដឹងអំពីការស្រាវជ្រាវដែលកំពុងដំណើរការដោយមានការពិចារណាយ៉ាងប្រុងប្រយ័ត្ន ដើម្បីកំណត់អំពីផលប៉ះពាល់រយៈពេលខ្លី និងរយៈពេលវែងអំពីទំនប់ទាំង៤៨ និងសំណើសុំសាងសង់ទំនប់បន្ថែមទៀត ទេ។ វានៅតែមិនច្បាស់ទេថាតើ វានឹងមានលទ្ធផលអ្វីខ្លះពីកិច្ចប្រឹងប្រែងរបស់គណៈកម្មការទន្លេមេគង្គ និងរបស់រដ្ឋាភិបាលក្នុងការស្តារឡើងវិញនូវប្រព័ន្ធជីវសិរីរាង្គចម្រុះដែលខូចខាតនៅក្នុងអាង និងស្តារឡើងវិញនូវពូជត្រីដែលប្រឈមផលប៉ះពាល់ដោយសារទំនប់នានាដែលកំពុងដំណើរការ។

បញ្ហាទាំងអស់នេះញ្ជាក់ថា រដ្ឋាភិបាលនៃប្រទេសទាំងបួននៅតាមទន្លេមេគង្គ ត្រូវការអនុវត្តអនុសាសន៍ នៅក្នុងរបាយការណ៍ ខែតុលា ឆ្នាំ២០១០ ស្តីពីការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រក្នុងការអនុវត្តគម្រោងវារីអគ្គិសនីនៅលើដងទន្លេមេនៃទន្លេមេគង្គ ដែលអនុសាសន៍នោះស្នើសុំផ្អាកការសាងសង់ទំនប់ទន្លេមេ ជាបណ្តោះអាសន្នរយៈពេល១០ឆ្នាំសិន ដើម្បីដោះស្រាយភាពមិនច្បាស់លាស់ និងក្តីបារម្ភយ៉ាងខ្លាំងអំពីគម្រោងអភិវឌ្ឍន៍បែបនោះ។[៤៦] ការស្នើសុំផ្អាកជាបណ្តោះអាសន្នរយៈ១០ឆ្នាំ ក្នុងការសាងសង់ទំនប់ថ្មី រួមទាំងទំនប់សាយ៉ាបួរីផង ពិតជាមានសក្តានុពល ធ្វើឱ្យសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ អាចមានលទ្ធភាពដោះស្រាយ ការទទួលខុសត្រូវរបស់ខ្លួន តាមមាត្រា៣ មាត្រ៧ និងមាត្រា៨នៃអនុសញ្ញាស្តីពីប្រព័ន្ធជីវសិរីរាង្គចម្រុះ ដើម្បីទប់ស្កាត់ផលប៉ះពាល់ធ្ងន់ធ្ងរចំពោះធនធាន ជីវសិរីរាង្គ ដែលប្រើរួមគ្នាដោយប្រទេសផ្សេងៗទៀត, ដើម្បីរកឱ្យឃើញនូវផលប៉ះពាល់លើប្រព័ន្ធជីវសិរីរាង្គដោយសារបណ្តាគម្រោង ដែលកំពុងអនុវត្ត និងគម្រោងដែលស្ថិតក្រោមការស្នើសុំ មុននឹងបន្តសាងសង់ទំនប់ថ្មីៗទៀត និងដើម្បីរកឱ្យឃើញ លទ្ធផលពីការស្តារប្រព័ន្ធសិរីរាង្គឡើងវិញ និងលទ្ធផលពីកិច្ចខិតខំប្រឹងប្រែងស្តារពូជត្រីឡើងវិញ (រួមទាំង ការស្តារឡើងវិញនូវពូជត្រីដែលប្រឈមការងាប់ផុតពូជ ដែលបើតាម សេចក្តីសន្និដ្ឋានដោយអ្នកជំនាញការថា ដោយសារតែ ត្រីទាំងនោះរស់នៅក្នុងតំបន់ដែលមានផលប៉ះពាល់ ដោយសារទំនប់សាយ៉ាបួរី) មុនពេលសាងសង់ទំនប់ថ្មីៗ។ ការសិក្សាវិភាគបន្ថែមទៀត ក៏ពិតជាអាចធ្វើឱ្យងាយស្រួលដល់ការពិនិត្យឡើងវិញលើឯកសារគាំទ្រការ សម្រេចចិត្តអនុម័តគម្រោង ដូចជា របាយការណ៍ស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន ដើម្បីបញ្ចូលទៅក្នុងការវិភាគ បន្ថែមទៀតអំពីផលប៉ះពាល់ដែលអាចនឹងកើនឡើង ដោយសារទំនប់សាយ៉ាបួរី នៅលើទន្លេមេគង្គ និងប្រជាជនដែលរស់នៅដោយពឹងផ្អែកលើទន្លេនេះ។

ប្រសិនបើគ្មានការយល់ដឹងបែបនេះទេ នោះសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ទំនងជាមិនអាចបំពេញការទទួលខុសត្រូវរបស់ខ្លួនទៅតាមមាត្រា៣, មាត្រា៧ និងមាត្រា៨នៃអនុសញ្ញាស្តីពីប្រព័ន្ធជីវសិរីរាង្គចម្រុះទេ

ព្រោះចំណាត់ការរបស់រដ្ឋាភិបាលអាចបណ្តាលឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរលើប្រព័ន្ធជីវសិរីវាង្គចម្រុះ និងរដ្ឋាភិបាលនៅតែមិនដឹងច្បាស់អំពីដំណើរការ និងសកម្មភាពមួយចំនួនដែលមាន ឬដែលអាចនឹងមានផលប៉ះពាល់យ៉ាងខ្លាំងលើប្រព័ន្ធជីវសិរីវាង្គចម្រុះ។

## ៤. សេចក្តីសម្រេចចិត្តក្នុងការអនុម័តទំនប់សាយ៉ាប៊ូរី តាមការស្នើសុំនោះ នឹងបណ្តាលឱ្យមានគ្រោះថ្នាក់យ៉ាងខ្លាំងដល់ប្រទេសជិតខាង ដែលផ្ទុយនឹងកាតព្វកិច្ចរបស់ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ក្នុងកិច្ចការពារមិនឱ្យមានគ្រោះថ្នាក់ឆ្លងដែន។

តាមច្បាប់អន្តរជាតិ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ត្រូវតែធានាថា រាល់សកម្មនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន មិនធ្វើឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថានរបស់ប្រទេសផ្សេងៗទៀតឡើយ។[៤៧] គោលការណ៍នេះត្រូវបានអះអាងបញ្ជាក់ដោយរដ្ឋាភិបាលទាំងបួននៅទន្លេមេគង្គក្រោម ទៅតាមកិច្ចព្រមព្រៀងនៃ គណៈកម្មការទន្លេមេគង្គ មាត្រា១ ("ធ្វើឱ្យការប្រើប្រាស់ចម្រុះមានប្រសិទ្ធភាពបំផុត និងធ្វើឱ្យប្រទេសនៅតាមដងទន្លេទទួលបានផលប្រយោជន៍រៀងខ្លួន") និងមាត្រា៣ ("ការពារបរិស្ថាន មិនឱ្យមានផលប៉ះពាល់ពីផែនការអភិវឌ្ឍន៍")។ គោលការណ៍នេះក៏មាន នៅក្នុងធម្មនុញ្ញពិភពលោកដើម្បីធម្មជាតិ ដែលតាមធម្មនុញ្ញនោះ ប្រទេសនីមួយៗត្រូវ "ធានាថា រាល់សកម្មភាពដែលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឬស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន មិនបង្កឱ្យមានការខូចខាតដល់ប្រព័ន្ធធម្មជាតិដែលស្ថិតនៅក្នុងប្រទេសផ្សេងៗទៀត ឬនៅក្នុងតំបន់នានាដែលស្ថិតនៅក្រៅដែនសមត្ថកិច្ចរបស់ប្រទេសរបស់ខ្លួនឡើយ"[៤៨], នៅក្នុងគោលការណ៍២នៃសេចក្តីប្រកាសទីក្រុងរីយ៉ូស្តីពីបរិស្ថាន និងគម្រោងអភិវឌ្ឍន៍ (សេចក្តីប្រកាសនៅទីក្រុងរីយ៉ូ) ដែលតាមគោលការណ៍នេះចែងថា "ប្រទេសនីមួយៗមានការទទួលខុសត្រូវក្នុងការធានាថា រាល់សកម្មភាពនៅក្នុងដែនសមត្ថកិច្ច ឬការគ្រប់គ្រងរបស់ខ្លួន មិនបង្កឱ្យមានការខូចខាតដល់បរិស្ថានរបស់ប្រទេសផ្សេងៗ ឬនៅក្នុងតំបន់ដែលស្ថិតនៅក្រៅដែនសមត្ថកិច្ចរបស់ខ្លួនឡើយ" និងនៅក្នុងមាត្រា១០នៃសន្ធិសញ្ញាមិត្តភាពនិងកិច្ចសហប្រតិបត្តិការតំបន់អាស៊ីអាគ្នេយ៍។[៤៩] ហេតុដូច្នេះ តាមកិច្ចព្រមព្រៀងទន្លេមេគង្គ និងតាមប្រភពច្បាប់អន្តរជាតិផ្សេងៗទៀត សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ មានកាតព្វកិច្ចក្នុងការ ការពារកុំឱ្យមានការខូចខាត និងទប់ស្កាត់មិនឱ្យមានការខូចខាតចំពោះបរិស្ថានរបស់ប្រទេសជិតខាង និងប្រជាជនរបស់ខ្លួនឡើយ។

សេចក្តីសម្រេចចិត្តជាប្រវត្តិសាស្ត្ររបស់តុលាការយុត្តិធម៌អន្តរជាតិ *គម្រោង Gabcikovo-Nagymaros (ប្រទេសហុងគ្រី/ប្រទេសស្លូវ៉ាគី)* បានបង្ហាញអំពីគោលការណ៍នេះនៅក្នុងការអនុវត្តជាក់ស្តែង។ ក្នុងករណីនេះ

តុលាការយុត្តិធម៌អន្តរជាតិបានធ្វើសេចក្តីសន្និដ្ឋានថា ប្រតិបត្តិការនៃជម្រើសដែលហៅថា Variant C សម្រាប់ប្រព័ន្ធទ្វារទឹកយ៉ាងធំមួយនោះ បានធ្វើឱ្យប្រទេសឆេកូស្លូវ៉ាគីដកហូតយកទៅប្រើប្រាស់ជាប្រយោជន៍ផ្ទាល់របស់ខ្លួន ពី៨០ ទៅ៩០ ភាគរយនៃទន្លេដានូប មុននឹងបង្ហូរទឹកទាំងនោះចូលទៅក្នុងដងទន្លេវិញ ទោះបីជាទន្លេដានូបជាផ្លូវទឹកអន្តរជាតិ ប្រើរួមគ្នាក៏ដោយ។ ទោះបីជាតុលាការបានធ្វើសេចក្តីសន្និដ្ឋាន តាមសន្ធិសញ្ញាឆ្នាំ១៩៧៧ថា ប្រទេសហុងគ្រីបានយល់ ព្រមឱ្យទប់ទំនប់ដានូប និងយល់ព្រមពង្វាងទឹករបស់ខ្លួនចូលទៅក្នុងព្រែកវាងនោះក៏ដោយ ក៏នោះគឺជាទង្វើទៅតាមស្ថានភាពនៃប្រតិបត្តិការរួមគ្នា និងចែកផលចំណេញគ្នាតែប៉ុណ្ណោះ។ តុលាការយុត្តិធម៌អន្តរជាតិ បាមធ្វើសេចក្តីសន្និដ្ឋានថា ការផ្អាកនិងការដកខ្លួនចេញរបស់ប្រទេសហុងគ្រីពីការយល់ព្រមនោះនាំឱ្យមានការរំលោភបំពានកាតព្វកិច្ចរបស់ប្រទេសហុងគ្រី ប៉ុន្តែ "នោះមិនអាចមានន័យថា ប្រទេសហុងគ្រីបានបោះបង់សិទ្ធិជាមូលដ្ឋានរបស់ខ្លួនចំពោះការចែកធនធានផ្លូវទឹកអន្តរជាតិ ដោយសមរម្យ និងស្មើគ្នានោះទេ" និងថា "ប្រទេសឆេកូស្លូវ៉ាគី ដែលកំពុងដាក់ទំនប់ Variant C ឱ្យដំណើរការនោះ មិនអនុវត្តសន្ធិសញ្ញាឆ្នាំ១៩៧៧នោះទេ ប៉ុន្តែផ្ទុយទៅវិញ បានរំលោភបទបញ្ញត្តិយ៉ាងច្បាស់របស់ខ្លួនមួយចំនួន និងថា ការធ្វើបែបនោះ ជាការប្រព្រឹត្តខុសនឹងច្បាប់អន្តរជាតិ។[៥០] តុលាការយុត្តិធម៌អន្តរជាតិបានគាំទ្រលទ្ធផលរបស់ខ្លួនដោយចង្អុលបង្ហាញនូវអ្វីដែលខ្លួនបានពិចារណាលើច្បាស់យ៉ាងចាស់ស្តីពីទន្លេឆ្លងដែន ដូចខាងក្រោម:

ដោយពាក់ព័ន្ធនឹងនាវាចរណ៍លើដងទន្លេអូដែ នៅឆ្នាំ១៩២៩ តុលាការយុត្តិធម៌អចិន្ត្រៃយ៍អន្តរជាតិបានបញ្ជាក់ថា:

"សហគមន៍ដែលទទួលផលប្រយោជន៍រួមពីទន្លេដែលអាចធ្វើនាវាចរណ៍បាន ក្លាយជាមូលដ្ឋាននៃសិទ្ធិស្របច្បាប់រួម ដែលជាលក្ខណៈយ៉ាងសំខាន់។ លក្ខណៈយ៉ាងសំខាន់នេះជាសមភាពយ៉ាងសុក្រឹត្យរបស់បណ្តារដ្ឋដែលស្ថិតនៅតាមដងទន្លេ ក្នុងការប្រើប្រាស់ទន្លេទាំងស្រុង និងក្នុងការបដិសេធសិទ្ធិអនុគ្រោះណាមួយរបស់ប្រទេសនៅតាមដងទន្លេណាមួយ ក្នុងទំនាក់ទំនងជាមួយប្រទេសផ្សេង" *(សមត្ថកិច្ចដែនដីរបស់គណៈកម្មការទន្លេអូដែ, ដីកាសម្រេចលេខ ១៦ ឆ្នាំ១៩២៩ តុលាការយុត្តិធម៌អចិន្ត្រៃយ៍អន្តរជាតិ, សំណុំរឿងជំពូក A លេខ២២៣ ទំព័រ២៧)*។

ការរីកចម្រើននៃច្បាប់អន្តរជាតិទំនើប ក៏បានពង្រឹងគោលការណ៍នេះសម្រាប់ការប្រើប្រាស់ផ្លូវទឹកអន្តរជាតិដែលមិនអាចធ្វើនាវាចរណ៍បាននេះដែរ ដូចមានជាភស្តុតាងស្រាប់ មហាសន្និបាទអង្គការសហប្រជាជាតិ បាន

អនុម័ត អនុសញ្ញា ថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៧ ទាក់ទងនឹងច្បាប់ស្តីពីការប្រើប្រាស់ផ្លូវទន្លេអន្តរជាតិដែលមិនអាចធ្វើនាវាចរណ៍។[៥១]

ដោយអនុវត្តហេតុផលនេះចំពោះទំនប់សាយ៉ាប៊ូរី ដូច្នេះសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ គ្មានសិទ្ធិធ្វើទំនប់កាត់ទន្លេមេនៃទន្លេមេគង្គនេះទេ ប្រសិនបើ សកម្មភាពនោះធ្វើឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់រដ្ឋាភិបាលដែលជាប្រទេសជិតខាង ដូចជាប្រទេសកម្ពុជា ប្រទេសថៃ និងប្រទេសវៀតណាម ដោយគ្មានការយល់ព្រមពីប្រទេសទាំងនេះទេ។ រដ្ឋាភិបាលនីមួយៗនៃបណ្តាប្រទេសនៅតាមដងទន្លេមេគង្គទាំងអស់ បានឯកភាពលើកិច្ចព្រមព្រៀងរួចហើយជាមួយ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ (កិច្ចព្រមព្រៀងទន្លេមេគង្គ) ដើម្បីការងារសិទ្ធិរបស់រដ្ឋាភិបាលនីមួយៗនៅតាមដងទន្លេមេគង្គ ដែលត្រូវទទួលបានចំណែកសមរម្យនិងស្មើគ្នាពីធនធានទន្លេ។ ហេតុដូច្នេះហើយ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ មិនអាចអនុម័តលើគម្រោងអភិវឌ្ឍន៍ណាមួយដែលបំផ្លាញច្រកយ៉ាងធំសម្រាប់ត្រីធ្វើដំណើរនោះទេ ព្រោះថា ប្រទេសនេះ មិនមែនជាម្ចាស់ជម្រកត្រី និងថា ប្រទេសនេះគ្មានសិទ្ធិធ្វើឱ្យខូចជម្រកត្រី ដើម្បីបុព្វសិទ្ធិរបស់ខ្លួនក្នុងការអភិវឌ្ឍនោះទេ។ កិច្ចព្រមព្រៀងទន្លេមេគង្គ ឆ្លើយតបនឹងគោលការណ៍ច្បាប់អន្តរជាតិ ទាក់ទងនឹងទន្លេឆ្លងដែន ដែលថា មានសមភាពយ៉ាងសុក្រឹតក្នុងចំណោមប្រទេសដែលស្ថិតនៅតាមដងទន្លេ ចំពោះការប្រើប្រាស់ទន្លេ។ ហេតុដូច្នេះហើយ បានជាតាមដំណើរការនៃនីតិវិធីសម្រាប់ ការជូនដំណឹង ការពិគ្រោះយោបល់ និងការយល់ព្រមជាមុននៃកិច្ចព្រមព្រៀងទន្លេមេគង្គ ការពិគ្រោះយោបល់ជាមុន "មិនមែនជាសិទ្ធិជំទាស់នឹងការប្រើប្រាស់ ហើយក៏មិនមែនជាសិទ្ធិឯកតោភាគីក្នុងការប្រើប្រាស់ទឹកដោយប្រទេសជាប់ទន្លេមេគង្គណាមួយ ដោយមិនពិចារណាអំពីសិទ្ធិរបស់ប្រទេសផ្សេងៗទៀតនៅតាមដងទន្លេឡើយ"។[៥២]

## ៥. សេចក្តីសម្រេចចិត្តអនុម័តទំនប់សាយ៉ាប៊ូរី តាមការស្នើសុំ ពិតជារំលោភបំពានលើ គោលការណ៍បង្ការទុកមុន ព្រោះ សេចក្តីសម្រេចចិត្តនេះ មិនបានដោះស្រាយភាពមិនច្បាស់លាស់ និងការព្រួយបារម្ភចំពោះមុខអំពីផលប៉ះពាល់ដោយសារទំនប់ និងមិនបានបង្ហាញថា សំណើកាត់បន្ថយផលប៉ះពាល់ទាំងនេះ អាចនឹងអនុវត្តបានជោគជ័យទេ។

តាមសេចក្តីប្រកាសទីក្រុងរីយ៉ូ រដ្ឋាភិបាលនីមួយៗត្រូវតែអនុវត្ត "វិធីគិតបង្ការទុកមុន" នៃគោលការណ៍១៥ "ដើម្បីការពារបរិស្ថាន" និង "នៅកន្លែងណាដែលមានការគំរាមកំហែងធ្វើឱ្យខូចខាតធ្ងន់ធ្ងរ ឬមិនអាចកែប្រែបាន ពេលនោះ មិនត្រូវប្រើហេតុផលនៃកង្វះភាពប្រាកដប្រជាផ្នែកវិទ្យាសាស្ត្រពេញលេញ ដើម្បីពន្យារិធានការប្រសិទ្ធភាពចំណាយដើម្បីការពារ ការខូចខាតបរិស្ថាននោះទេ"។[៥៣] សេចក្តីសម្រេចចិត្តរបស់រដ្ឋាភិបាលឡាវ ក្នុងការអនុម័ត

គម្រោងទំនប់សាយ៉ាបួរី ដោយផ្អែកលើភាពខ្វះចន្លោះ នៅក្នុងរបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាន (ដូចបានលើកមក ពិភាក្សាខាងលើ) ផ្ទុយនឹងគោលការណ៍គិតបង្ការមុន យ៉ាងតិចពីរចំណុចដូចខាងក្រោម ។

ចំណុចទី១: សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ មិនបានបង្ហាញថា បានចាត់វិធានការដើម្បីដោះស្រាយអនុសាសន៍ចាំបាច់ៗមួយចំនួនដូចមាននៅក្នុងរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ដើម្បីផ្អាកដំណើរការសាងសង់ទំនប់ទន្លេមេជាបណ្ដោះអាសន្នរយៈពេល១០ឆ្នាំ ដើម្បីទុកឱកាសឱ្យស្វែងយល់ច្បាស់ និងព្យាករណ៍អំពីប្រសិទ្ធភាពរយៈពេលខ្លី និងរយៈពេលវែង ពីគម្រោងអភិវឌ្ឍន៍ទំនប់លើទន្លេមេនៃទន្លេមេគង្គ។ ការវាយតម្លៃបរិស្ថាន ជាយុទ្ធសាស្ត្រនេះជាមធ្យោបាយសម្រាប់ "លើកកម្ពស់ [] ដោយផ្ទាល់ចំពោះព័ត៌មានគោល និងក្របខ័ណ្ឌនៃការវាយតម្លៃ ដើម្បីឱ្យរដ្ឋាភិបាលធ្វើការពិនិត្យជាបន្តបន្ទាប់លើ របាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថានដែលផ្ដោតលើគម្រោងជាក់លាក់ ដែលរៀបចំដោយក្រុមហ៊ុនអភិវឌ្ឍន៍។ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រនេះក៏ជាមធ្យោបាយដើម្បីផ្ដល់ព័ត៌មានដែរថា តើគណៈកម្មការទន្លេមេគង្គអាចលើកកម្ពស់ការគាំទ្រប្រទេសសមាជិកទន្លេមេគង្គដោយរបៀបណា នៅពេលដែលដំណើរការជាផ្លូវការតាមកិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ១៩៩៥ ដែលតម្រូវឱ្យមានការពិគ្រោះយោបល់ជាមុនលើសំណើសាងសង់ទំនប់លើទន្លេមេនីមួយៗ ត្រូវបានចាប់ផ្ដើម (គឺ តាមដំណើរការនៃនីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ និងការព្រមព្រៀងជាមុន)" ។[៥៤]

ជាអកុសល អ្វីដែលបានរៀបរាប់ខាងលើនេះ មិនបានកើតឡើងចំពោះទំនប់សាយ៉ាបួរីទេ ព្រោះ របាយការណ៍ស្ដីពីការវាយតម្លៃបរិស្ថានជាយុទ្ធសស្ត្រនោះ ត្រូវបានប្រកាសជាសាធារណៈ ក្រោយការរៀបចំឯកសារសំខាន់ៗ ដើម្បីសម្រេចចិត្តលើសំណើគម្រោងទំនប់ ដូចជា ឯកសារសិក្សាស្រាវជ្រាវអំពីលទ្ធភាព របាយការណ៍ស្ដីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងរបាយការណ៍ស្ដីពីការវាយតម្លៃផលប៉ះពាល់សង្គម។ អនុសាសន៍ស្នើសុំផ្អាកដំណើរការសាងសង់ទំនប់ជាបណ្ដោអាសន្នរយៈពេល១០ឆ្នាំ នៃរបាយការណ៍ស្ដីពីការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រនេះ ត្រូវគ្នានឹង "វិធីសាស្ត្រគិតបង្ការទុកមុន" ដើម្បីស្វែងយល់ច្បាស់លាស់អំពីផលប៉ះពាល់ដែលបណ្ដាលមកពីការសាងសង់ទំនប់ថ្មីមុននិងធ្វើសេចក្ដីសន្និដ្ឋានបញ្ចៀសផលប៉ះពាល់បែបនោះ។ សេចក្ដីសម្រេចចិត្តរបស់ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ក្នុងការអនុម័តទំនប់សាយ៉ាបួរី មានទិសដៅផ្ទុយដោយមានការរំលោភបំពានលើវិធីសាស្ត្រគិតបង្ការមុននេះ។

ចំណុចទី២: ដូចបានលើកឡើងខាងលើ ក្រុមអ្នកវិទ្យាសស្ត្រ និងអ្នកប្រកបវិជ្ជាជីវៈឯករាជ បានបញ្ជាក់បង្ហាញនូវក្ដីបារម្ភយ៉ាងខ្លាំងថា សំណើសាងសង់រចនាសម្ព័ន្ធជណ្ដើរសម្រាប់ត្រីនៅទំនប់សាយ៉ាបួរីនោះ មិនសមប្រកបទេ និងមិនអាចឱ្យត្រីជាច្រើនប្រភេទដែលកំពុងរស់នៅក្នុងតំបន់ដែលប្រឈមផលប៉ះពាល់ដោយសារទំនប់សាយ៉ាបួរី ដែលជា

ច្រកចេញចូលនោះ អាចឆ្លងកាត់បានទេ។ តាមការប្រើប្រាស់ "វិធីសាស្ត្របង្ការទុកមុន" នេះ សំណើបច្ចេកវិទ្យាសាងសង់ជណ្តើរសម្រាប់ត្រី សម្រាប់ទំនប់ទន្លេមេណាមួយនោះ ត្រូវតែមានកំណត់ត្រាច្បាស់លាស់អំពីជោគជ័យក្នុងស្ថានភាពដូចគ្នា មុននឹងត្រូវដាក់ស្នើសុំសាងសង់នៅទន្លេមេនេះ។ ចំណុចនេះត្រូវគ្នានឹងការប្រកាសអាសន្ន ពីអ្នកវិភាគអំពីការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ។ អ្នកវិភាគនោះបានសន្និដ្ឋានថា "ទន្លេមេនៃទន្លេមេគង្គ ដាច់ខាតមិនត្រូវប្រើប្រាស់ទាល់តែសោះ សម្រាប់ជាករណីសាកល្បង សម្រាប់ផ្តល់ និងកែលម្អបច្ចេកវិទ្យាទំនប់វារីអគ្គិសនីទាំងស្រុងនោះទេ"។[៥៥] ប៉ុន្តែ រចនាសម្ព័ន្ធជណ្តើរសម្រាប់ត្រីដែលគ្មានឆ្លងកាត់ការសាកល្បង សម្រាប់ទំនប់សាយ៉ាប៊ូរីនោះ ច្បាស់ណាស់គឺជា "ករណីសាកល្បង" ដែលការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ទទូចស្នើសុំនេះ មិនដែលត្រូវបានអនុវត្តទេ។

សង្ខេបមកវិញ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ខកខានមិនបានអនុវត្ត ការពិចារណាមុន ដើម្បីឱ្យយល់ច្បាស់អំពីប្រសិទ្ធភាពនៃគម្រោងអភិវឌ្ឍន៍ទំនប់ទន្លេមេ មុននឹងអនុម័តដំណើរការសាងសង់ទំនប់ សាយ៉ាប៊ូរីទេ។ រដ្ឋាភិបាលក៏មិនបានអនុវត្ត ការពិចារណាមុន ដើម្បីធានាសំណើបច្ចេកវិទ្យារចនាសម្ព័ន្ធជណ្តើរត្រីនៅទំនប់នេះ អាចឱ្យត្រីជាច្រើនប្រភេទនៅក្នុងទន្លេនេះឆ្លងកាត់បាន។ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និង ប្រទេសបីទៀត នៅតាមដងទន្លេត្រូវតែគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការពិចារណាជាមុននេះ ដោយឯកភាពទៅតាមអនុសាសន៍របស់របាយការណ៍ស្តីពីការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ដែលស្នើសុំផ្អាកដំណើរការសាងសង់ទំនប់ជាបណ្តោះអាសន្នរយៈពេល១០ឆ្នាំ។

## ៦. ប្រទេសកម្ពុជា ប្រទេសថៃ និងប្រទេសវៀតណាម មានសិទ្ធិ និងកាតព្វកិច្ច ការពារមិនឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីទំនប់សាយ៉ាប៊ូរី ចំពោះទន្លេមេគង្គ។ រដ្ឋាភិបាលនៃប្រទេសទាំងបីនេះ មានសិទ្ធិស្របច្បាប់ក្នុងការទទួលដំណោះស្រាយផ្នែកហិរញ្ញវត្ថុ សម្រាប់ផលប៉ះពាល់ធ្ងន់ធ្ងរ ដែលកើតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន រៀងៗខ្លួន។

### ក. កាតព្វកិច្ចក្នុងការជំទាស់នឹងគម្រោងអភិវឌ្ឍន៍ ដែលគំរាមកំហែងដល់ការប្រើប្រាស់ចម្រុះនូវទន្លេមេគង្គ។

មាត្រា៣នៃកិច្ចព្រមព្រៀងទន្លេមេគង្គតម្រូវឱ្យប្រទេសហត្ថលេខីនីមួយៗ "ការពារបរិស្ថាន ធនធានធម្មជាតិ ប្រព័ន្ធសីរាង្គរស់ និងលក្ខខណ្ឌទឹក និងតុល្យភាពប្រព័ន្ធជីវសីរាង្គរបស់អាងទន្លេមេគង្គ មិនឱ្យមានការបំពុល និងផលប៉ះពាល់ផ្សេងៗទៀតដែលបណ្តាលមកពីផែនការអភិវឌ្ឍន៍ណាមួយ និងមកពីការប្រើប្រាស់ទឹក និងធនធានដែលពាក់ព័ន្ធនៅក្នុងអាងទន្លេមេគង្គ"។ សេចក្តីបង្គាប់នេះ អនុវត្តចំពោះប្រទេសដែលជា

ហត្ថលេខីទាំងអស់ និងចំពោះគម្រោងអភិវឌ្ឍន៍ណាមួយ ដោយមិនគិតអំពីការអភិវឌ្ឍនោះកើតឡើងនៅទីណាឡើយ។ ដូច្នេះ តាមកិច្ចព្រមព្រៀងទន្លេមេគង្គនេះ ភាគីនីមួយៗបានយល់ព្រម និងសង្ឃឹមថា ប្រទេសដែលជាហត្ថលេខីផ្សេងៗទៀតទាំងអស់ នឹងអនុវត្តសិទ្ធិរបស់ខ្លួនដើម្បីជំទាស់សំណើប្រើប្រាស់ទន្លេ ដែលការប្រើប្រាស់នោះ មានការគំរាមបំផ្លាញយ៉ាងធ្ងន់ធ្ងរ ដល់ប្រព័ន្ធជីវសិរាង្គនៃទន្លេដែលប្រើប្រាស់រួមគ្នានេះ និងគំរាមបង្ខូចស្ថានភាពសង្គម និងសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋដែលអាស្រ័យផលទន្លេ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

តាមរយៈការជំទាស់បែបនេះ ប្រទេសដែលជាហត្ថលេខីនីមួយៗ អាចអនុវត្តនូវអ្វីដែលជាកាតព្វកិច្ចយ៉ាងសំខាន់បំផុតរបស់ខ្លួន ទៅតាមកិច្ចព្រមព្រៀងទន្លេមេគង្គ ដែលមាត្រា១នៃកិច្ចព្រមព្រៀងនេះតម្រូវឱ្យរដ្ឋាភិបាលនីមួយៗ "សហការគ្នា ក្នុងការប្រើប្រាស់ គ្រប់គ្រង និងរក្សាទឹក និងធនធានពាក់ព័ន្ធ របស់អាងទន្លេមេគង្គទៅតាមលក្ខណៈ ដែលធ្វើឱ្យការប្រើប្រាស់ចម្រុះ និងផលប្រយោជន៍ទៅវិញទៅមក របស់ប្រទេសនៅតាមដងទន្លេទាំងអស់ទទួលបាន លទ្ធផលខ្ពស់បំផុត និងបន្ថយផលប៉ះពាល់ដែលអាចបណ្តាលមកពីព្រឹត្តិការណ៍ធម្មជាតិ និងសកម្មភាព បង្កើតឡើងដោយមនុស្ស ថយចុះនៅកម្រិតទាបបំផុត"។ កាតព្វកិច្ចក្នុងការការពារទន្លេមេគង្គ និងជំទាស់គម្រោងអភិវឌ្ឍន៍ដែលបង្ខូចការប្រើប្រាស់ទន្លេចម្រុះនេះ មានចែងនៅក្នុងកិច្ចព្រមព្រៀងទន្លេមេគង្គ ដែលជាច្បាប់អន្តរជាតិ ម្យ៉ាងទៀត កាតព្វកិច្ចនេះក៏មានចែងនៅក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេសនីមួយៗ គឺប្រទេស កម្ពុជា[៥៦] សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ[៥៧] ប្រទេសថៃ[៥៨] និងប្រទេសវៀតណាម[៥៩]ដែរ។

ប្រទេសកម្ពុជា ថៃ និងប្រទេសវៀតណាម បានលើកឡើង ឬប្រាប់អំពីក្តីព្រួយបារម្ភយ៉ាងខ្លាំងរៀងខ្លួន ពីភាគីពាក់ព័ន្ធរបស់ខ្លួន អំពីសំណើទំនប់សាយ៉ាប៊ូរី។ ប្រទេសកម្ពុជាបានស្នើសុំថា រយៈពេលនៃការពិគ្រោះយោបល់ត្រូវពន្យារពេល និងពន្យល់ នៅក្នុងរបាយការណ៍ស្តីពីនីតិវិធីសម្រាប់ ការជូនដំណឹង ការពិគ្រោះយោបល់ និងការយល់ព្រមជាមុន "មានសេចក្តីត្រូវការតាមអនុសាសន៍ឱ្យមាន ការសិក្សា និងវាយតម្លៃយ៉ាងល្អិតល្អន់ អំពីផលប៉ះពាល់បរិស្ថានឆ្លងដែន រួមទាំងការវាយតម្លៃផលប៉ះពាល់កើនឡើងផង"។[៦០] ប្រទេសថៃបាននិយាយបញ្ជាក់ឡើងវិញ អំពីការបារម្ភរបស់ភាគីពាក់ព័ន្ធរបស់ខ្លួនថា "ការវាយតម្លៃផលប៉ះពាល់បរិស្ថាន មិនបានកំណត់ច្បាស់លាស់អំពីផលប៉ះពាល់លើប្រព័ន្ធជីវសិរាង្គ និងរបបទឹកហូរ ក៏ដូចជា ផលប៉ះពាល់ឆ្លងដែនចំពោះប្រទេសថៃដែរ" និងថា "ដោយសារតែគ្មានព័ត៌មានគ្រប់គ្រាន់សម្រាប់ការពិចារណា ... ដើម្បីពន្យាររយៈពេលកំណត់ នៃនីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ និងការព្រមព្រៀងជាមុន ដូច្នេះមិនត្រូវដាក់កម្រិតត្រឹមតែ៦ខែនោះទេ"។[៦១]

របាយការណ៍ស្តីពីនីតិវិធីសម្រាប់ ការជូនដំណឹង ការពិគ្រោះយោបល់ និងការព្រមព្រៀងជាមុន របស់ប្រទេសវៀតណាមបានលើកឡើងអំពីការបារម្ភគួរឱ្យកត់សម្គាល់អំពីគម្រោងនេះ ដូចខាងក្រោម។

ដោយមានក្តីបារម្ភយ៉ាងខ្លាំងបែបនេះ ប្រទេសវៀតណាមបានរកឃើញថា រយៈពេលរិតត្បិតនៃការពិគ្រោះយោបល់ជាមុននេះ មិនគ្រប់គ្រាន់សម្រាប់សម្រួលដល់ការសម្រេចជោគជ័យនានាដែលជាគោលបំណងរបស់នីតិវិធីនេះទេ។ ដោយផ្អែកលើលទ្ធផលដែលបានរកឃើញខាងលើនេះ ដូច្នេះហើយ ប្រទេសវៀតណាម ស្នើសុំយ៉ាងទទូចថា ការសម្រេចចិត្តអនុម័តគម្រោងវារីអគ្គិសនីសាយ៉ាប៊ូរី ក៏ដូចជា សំណើគម្រោងវារីអគ្គិសនីផ្សេងៗទៀតនៅទន្លេមេនៃទន្លេមេគង្គ ត្រូវពន្យារពេលយ៉ាងតិច១០ឆ្នាំ តាមអនុសាសន៍យ៉ាងច្រើនលើសលុបពីសហគមន៍នានា អង្គការមិនមែនរដ្ឋាភិបាលថ្នាក់ជាតិ និងតំបន់ និងពីដៃគូអភិវឌ្ឍន៍ជាច្រើនទៀត។ ត្រូវមើលឱ្យឃើញថា ការពន្យារពេលនេះ ជាវិធីមួយដើម្បីផ្តល់ពេលវេលាត្រូវការយ៉ាងច្រើន ដើម្បីឱ្យរដ្ឋាភិបាលនានានៅតាមដងទន្លេមេគង្គ អនុវត្តការសិក្សាយ៉ាងល្អិតល្អន់ និងកាន់តែផ្តោតលើបរិមាណនៃផលប៉ះពាល់កើនឡើងទាំងអស់ដែលអាចនឹងកើតមានដោយសារគម្រោងទឹកធ្លាក់ពីទំនប់ចូលទៅក្នុងទន្លេមេនៃទន្លេមេគង្គ ជាពិសេស លក្ខណៈទឹកធ្លាក់ឆ្លងដែនចូលទៅក្នុងទន្លេមេគង្គ រួមទាំងផ្នែកនៃតំបន់ដីសណ្តទន្លេមេគង្គរបស់ប្រទេសវៀតណាមផង។[៦២]

ដូចបានបញ្ជាក់ខាងលើរួចហើយថា រដ្ឋាភិបាលនៃប្រទេសទាំងបីបានលើកឡើងអំពីក្តីបារម្ភថា គ្មានព័ត៌មានគ្រប់គ្រាន់សម្រាប់វាយតម្លៃយ៉ាងសមហេតុផលអំពីផលប៉ះពាល់ឆ្លងដែនដោយទំនប់នេះទេ។ លើសពីនេះទៅទៀត តាមយើងដឹង សេចក្តីអំពាវឱ្យមានការពិគ្រោះយោបល់បន្ថែមទៀតរវាងរដ្ឋាភិបាល និងប្រជាជនដែលប្រឈមផលប៉ះពាល់ តាមរយៈ ដំណើរការនៃនីតិវិធីសម្រាប់ ការជូនដំណឹង ការពិគ្រោះយោបល់ និងការព្រមព្រៀងជាមុននោះ មិនត្រូវបានអនុវត្តទេ។ ប្រសិនបើ ក្នុងចំណោមរដ្ឋាភិបាលទាំងនោះ មានរដ្ឋាភិបាលមួយ ឬច្រើនប្រកាន់ទស្សនៈថា ទំនប់សាយ៉ាប៊ូរី នឹងបណ្តាលឱ្យមាន "ផលប៉ះពាល់ដោយសារផែនការអភិវឌ្ឍន៍ និងដោយសារការប្រើប្រាស់ទឹក និងធនធានពាក់ព័ន្ធ នៅក្នុងអាងទន្លេមេគង្គ" ដូច្នេះរដ្ឋាភិបាល មានកាតព្វកិច្ចត្រូវជំទាស់នឹងសំណើប្រើប្រាស់នោះ ដើម្បីការពារ ផលប្រយោជន៍ចម្រុះពីទន្លេមេគង្គដែលរដ្ឋាភិបាលកំពុងប្រើប្រាស់។

## ខ. សំណងចុងក្រោយ ដើម្បីដោះស្រាយផលប៉ះពាល់ធ្ងន់ធ្ងរដោយសារទំនប់នេះ នៅក្នុងដែនសមត្ថកិច្ចរបស់ប្រទេសផ្សេង។

ប្រសិនបើទំនប់សាយាប៊ូរីត្រូវបានសាងសង់ នោះប្រទេសកម្ពុជា ថៃ និងប្រទេសវៀតណាម សុទ្ធតែមាន

សិទ្ធិទទួលសំណងស្របច្បាប់ សម្រាប់ការខូចខាតដោយសារទំនប់នេះ ដែលកើតមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ដូចមានការទទួលស្គាល់ដោយតុលាការយុត្តិធម៌អន្តរជាតិថា "វាជាវិធានយ៉ាងរឹងមាំរបស់ច្បាប់អន្តរជាតិ ដែលរដ្ឋណាមួយទទួលរងការខូចខាតមានសិទ្ធិស្របច្បាប់ក្នុងការទទួលសំណងសម្រាប់ការខូចខាត ពីរដ្ឋដែលបានប្រព្រឹត្តខុសច្បាប់អន្តរជាតិ"។[៦៣] សិទ្ធិទទួលសំណងនេះក៏ផ្អែកលើមាត្រា៧[៦៤] និងមាត្រា៨[៦៥] នៃកិច្ចព្រមព្រៀងទន្លេមេគង្គដែរ។

ប្រទេសទាំងនោះក៏មានកាតព្វកិច្ចដូចគ្នានេះដែរ ក្នុងការធ្វើជាតំណាងរបស់ប្រជាជនរបស់ខ្លួន ក្នុង ការស្វែងរកដំណោះស្រាយ និងសំណងសម្រាប់ការខូចខាតបរិស្ថានដែលកើតមានចំពោះប្រជាជនរបស់ខ្លួន ដោយមិនគិតថាការខូចខាតនោះមានប្រភពដើមមកពីទីណាឡើយ។ កាតព្វកិច្ចនេះ ត្រូវបានទទួលស្គាល់ដោយគណៈកម្មការ ទទួលបន្ទុកការសាងសង់ទំនប់ពិភពលោក ដែលទទួលស្គាល់ថា "ច្បាប់អន្តរជាតិជាធរមាននានាបានបញ្ជាក់យ៉ាងច្បាស់អំពីការសន្មតតាមផ្លូវច្បាប់សម្រាប់សិទ្ធិទទួលបាននូវដំណោះស្រាយ ឬទទួលបានសំណងដែលឆ្លើយតបនឹងក្របខណ្ឌច្បាប់របស់ប្រទេសជាច្រើនដែរ។ ការទទួលខុសត្រូវក្នុងការផ្តួចផ្តើមដំណើរការទូទាត់សំណងគឺអាស្រ័យលើរដ្ឋាភិបាល។ ប្រជាពលរដ្ឋដែលប្រឈមផលប៉ះពាល់ អាចប្តឹងទារសំណងទៅរដ្ឋាភិបាល" និងថា "នោះគឺជាការទទួលខុសត្រូវរបស់រដ្ឋក្នុងការការពារប្រជាពលរដ្ឋរបស់ខ្លួន រួមទាំងការងារសិទ្ធិទទួលបានសំណងសមរម្យផង"។[៦៦] ការសិក្សានេះក៏មានការឆ្លុះបញ្ចាំងអំពីគោលការណ៍ទី១០នៃសេចក្តីប្រកាសទីក្រុងរីយ៉ូដែលបញ្ជាក់អំពីផ្នែកដែលពាក់ព័ន្ធនោះ ថា "ប្រទេសនីមួយៗត្រូវសម្រួល និងលើកទឹកចិត្តឱ្យមានការផ្សព្វផ្សាយ និងការចូលរួមជាសាធារណៈ ដោយធ្វើឱ្យមានព័ត៌មានយ៉ាងទូលំទូលាយ។ សិទ្ធិទទួលបានចំណាត់ការតាមច្បាប់និងរដ្ឋបាលប្រកបដោយប្រសិទ្ធភាព រួមមានការដោះស្រាយ និងទូទាត់សំណង ត្រូវតែផ្ទាល់ជូន។[៦៧]

ចំណុចជាគន្លឹះដើម្បីប្រើសិទ្ធិ និងបំពេញកាតព្វកិច្ចក្នុងការដោះស្រាយ និងទូទាត់សំណងចំពោះការខូចខាតបរិស្ថានគឺ ប្រទេសដែលប្រឈមផលប៉ះពាល់ត្រូវចងក្រងឯកសារអំពីផលប៉ះពាល់ធ្ងន់ធ្ងរដែលបណ្តាលមកពីគម្រោងនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនផ្ទាល់។ មាត្រា៧នៃកិច្ចព្រមព្រៀងទន្លេមេគង្គតម្រូវឱ្យមាន "ភស្តុតាងត្រឹមត្រូវនិងមានសុពលភាព" អំពីផលប៉ះពាល់ទាំងនេះ។ ហេតុដូច្នេះហើយ ប្រសិនបើ ទាំងប្រទេសកម្ពុជា ទាំងប្រទេសថៃ និងទាំងប្រទេសវៀតណាម ប្រកាន់ទស្សនៈថា ទំនប់សាយ៉ាប៊ូរីបណ្តាលឱ្យមានផលប៉ះពាល់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដូច្នេះ ប្រទេសនីមួយៗនោះត្រូវគាំទ្រកម្មវិធីមួយដើម្បីបង្ហាញអំពីផលប៉ះពាល់ពីទំនប់នេះនាពេលអនាគត។ ក្នុងខណៈដែលគ្មានការអនុវត្តសាមញ្ញណាមួយដែលធ្វើសកម្មភាពជាច្រើនផ្សេងទៀត នៅក្នុងទន្លេមេគង្គ និងធ្វើឱ្យមានផលប៉ះពាល់ជាច្រើនដល់ទន្លេមេគង្គ នេះគេអាចដឹងថា អាចត្រូវជួលអ្នកផ្សេងឱ្យចុះវាយតម្លៃដោយឯករាជ អំពី

លក្ខខណ្ឌបរិស្ថានក្នុងស្ថានភាពបច្ចុប្បន្ន នៅតំបន់ដែលស្ថិតនៅជិតគម្រោង អមដោយការវិភាគរបស់អ្នកជំនាញឯករាជ ថា តើបណ្តាលក្ខខណ្ឌទាំងនោះ មានភាពខុសគ្នាដូចម្តេចនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋាភិបាល ដែលបណ្តាលមកពីទំនប់នេះ។ ការវាយតម្លៃនេះក៏អាចបញ្ចូលការវិភាគស្ថានភាពសេដ្ឋកិច្ចដែលត្រូវខាតបង់ផ្នែកហិរញ្ញវត្ថុយ៉ាងខ្លាំង ដែលបណ្តាលមកពីផលប៉ះពាល់ទាំងនោះ (ឧទាហរណ៍ ផលប៉ះពាល់លើជលផល ការបាត់បង់កករដីនៅបាតទន្លេ ទឹកបាត់បង់គុណភាព)។ ចំណុចគោលទាំងនេះ ក្រោយមកអាចត្រូវយកមកប្រើដើម្បីធ្វើការវាស់វែង ផលប៉ះពាល់បរិស្ថាន និងសេដ្ឋកិច្ច និងសង្គម ដែលអាចចាត់ទុកថា មានពាក់ព័ន្ធនឹងទំនប់នេះ។

សង្ខេបមកវិញ កាតព្វកិច្ចត្រូវការពារទន្លេមេគង្គ និងប្រជាជនដែលអាស្រ័យផលលើទន្លេនេះ មិនមែនមានតែសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវទេ តែត្រូវរួមទាំងរដ្ឋាភិបាលប្រទេសជិតខាងថែមទៀតផង។

## អនុសាសន៍

យើងយល់ថា មានកិច្ចប្រជុំក្រុមប្រឹក្សានៃគណៈកម្មការទន្លេមេគង្គនៅក្នុងខែវិច្ឆិកា ឆ្នាំ២០១១នេះ ដើម្បីពិភាក្សានិងព្យាយាមដោះស្រាយនូវក្តីបារម្ភមួយចំនួនរបស់ប្រទេសកម្ពុជា ប្រទេសថៃ និងប្រទេសវៀតណាម ពាក់ព័ន្ធនឹងសេចក្តីសម្រេចចិត្តរបស់ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវក្នុងការអនុម័តការសាងសង់ទំនប់សាយ៉ាប៊ូរី។ ដើម្បីជួយដល់ការពិគ្រោះយោបល់ជាផ្លូវការរបស់ភាគីចូលរួមនោះ យើងសូមផ្តល់ជូនអនុសាសន៍បីជាគំនិតផ្តួចផ្តើមមុនកិច្ចប្រជុំរួមរបស់ក្រុមប្រឹក្សា ដែលអាចជាព័ត៌មាន និងជួយដោះស្រាយវិវាទទាក់ទងនឹងទំនាស់នៃការប្រើប្រាស់ទន្លេមេគង្គ។

១. <u>ផ្តល់មូលនិធិសម្រាប់ការវិភាគឯករាជបន្ថែមទៀត អំពីឯកសារពាក់ព័ន្ធនឹងការសម្រេចចិត្តអនុម័តគម្រោងរួមមាន របាយការណ៍ស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងផលប៉ះពាល់ឆ្លងដែនដែលអាចនឹងកើតឡើងដោយសារទំនប់សាយ៉ាប៊ូរី</u>។ ក្នុងស្ថានភាពដែលមានការចោទប្រកាន់ថាមានទំនាស់បែបនេះ គ្មានអ្វីជាទីគាប់ចិត្តជាងការវិភាគឯករាជអំពីផលបះពាល់ ដោយសារគម្រោងអភិវឌ្ឍន៍ ទៅលើបរិស្ថាន សេដ្ឋកិច្ច និងសង្គមនោះទេ។ ការវិភាគឯករាជ និងកាន់តែល្អិតល្អន់ អមដោយការចុះស៊ើបអង្កេតនៅមូលដ្ឋានដោយអ្នកជំនាញ មានបទពិសោធន៍ អំពីស្ថានភាព ឬលក្ខខណ្ឌបច្ចុប្បន្ន នៅការដ្ឋានស្នើសាងសង់ទំនប់ អាចជាមូលដ្ឋានសម្រប់ ការងារដោះស្រាយវិវាទ និងអាចជាការចងក្រងឯកសារបន្ថែមអំពីរបៀបពិនិត្យលើឯកសារពាក់ព័ន្ធនឹងការសម្រេចចិត្តបន្ថែម។ លើសពីនេះទៅទៀត វាជាការសំខាន់ណាស់ដែលត្រូវអនុវត្ត ការវិភាគបន្ថែមទៀតអំពីផលប៉ះពាល់ឆ្លងដែនដែលបណ្តាលមកពីទំនប់នេះ។ ត្រូវបញ្ចូលការវិភាគនេះទៅក្នុង

របាយការណ៍ថ្មីស្តីពី ការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងនៅពេលធ្វើដូច្នេះហើយ របាយការណ៍ស្តីពី ការវាយតម្លៃផលប៉ះពាល់បរិស្ថានថ្មីនេះ ត្រូវយកទៅប្រើជាមូលដ្ឋាន សម្រាប់ចូលរួមពិគ្រោះយោបល់ ប្រកបដោយផ្លែផ្កា ជាមួយប្រជាជនដែលប្រឈមផលប៉ះពាល់នៅក្នុងប្រទេសទាំងបួននៅតាមទន្លេមេគង្គក្រោម។

២. <u>បើកសន្និសីទទាក់ទងនឹងអនុសញ្ញាស្តីពីប្រព័ន្ធជីវសរីរាង្គចម្រុះ ដោយមានភាគីពាក់ព័ន្ធចូលរួមដើម្បីពិភាក្សាអំពីផលវិបាកនៃការបាត់បង់ប្រព័ន្ធជីវសរីរាង្គ ដែលអាចបណ្តាលមកពីគម្រោងនេះ</u>។ ជាកិច្ចប្រឹងប្រែងដើម្បីការពារកុំឱ្យមានការបាត់បង់ប្រព័ន្ធជីវសរីរាង្គ និងកាត់បន្ថយផលប៉ះពាល់ដែលបណ្តាលឱ្យការបាត់បង់ប្រព័ន្ធជីវសរីរាង្គ ពីគម្រោងទំនប់នេះ រដ្ឋាភិបាលណាមួយនៃប្រទេសទាំង៤ដែលស្ថិតនៅតាមទន្លេមេគង្គក្រោម អាចផ្តល់គំនិតទៅលេខាធិការដ្ឋាននៃអនុសញ្ញាស្តីពីប្រព័ន្ធជីវសរីរាង្គចម្រុះ និងស្នើសុំបើកកិច្ចប្រជុំមួយដែលមានភាគីពាក់ព័ន្ធចូលរួម ដោយអនុលោមទៅតាម កថាខណ្ឌ២នៃមាត្រា២៣នៃអនុសញ្ញាស្តីពីប្រព័ន្ធជីវសរីរាង្គចម្រុះ។ តាមបទបញ្ញត្តិនេះ "ត្រូវបើកកិច្ចប្រជុំសន្និសីទវិសាមញ្ញដែលមានភាគីពាក់ព័ន្ធចូលរួម នៅពេលណាមួយដែលអង្គសន្និសីទនេះសន្មតថាជាឱកាសចាំបាច់ ឬត្រូវបើកកិច្ចប្រជុំ ទៅតាមការស្នើសុំជាលាយលក្ខណ៍អក្សរដោយភាគីណាមួយ ក្នុងរយៈមិនលើសពី៦ខែ ក្រោយពីលេខាធិការដ្ឋានបានជូនដំណឹងអំពីសំណូមពរនេះ ក្នុងករណីដែលសំណើសុំនេះ មានការគាំទ្រយ៉ាងតិចមួយភាគបីនៃភាគីទាំងអស់"។

៣. <u>អនុវត្តតាម និងគាំទ្រការចរចាដោយស្មោះត្រង់ ទោះបីជា ព្រមឬមិនព្រមអនុម័តគម្រោងទំនប់សាយ៉ាប៊ូរីនេះក៏ដោយ</u>។ ប្រទេសកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រទេសថៃ និងប្រទេសវៀតណាម បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទន្លេមេគង្គ ដោយសង្ឃឹមថា កិច្ចព្រមព្រៀងនេះអាចអនុវត្តបានទៅតាមច្បាប់អន្តរជាតិ។ ប្រសិនបើ រដ្ឋាភិបាលនៃប្រទេសទាំងបួន ឈានដល់ដំណាក់កាលគាំងទៅមុខលែងរួច ដោយហេតុថា គាំទ្រ ឬមិនគាំទ្រដំណើរការសាងសង់ទំនប់នេះក្តី ភាគីទាំងអស់ត្រូវខិតខំធ្វើការទាំងអស់គ្នាដើម្បីដោះស្រាយគំនិតខ្វែងគ្នានោះ ទៅតាមនីតិវិធីដោះស្រាយវិវាទ តាមជំពូក៤នៃកិច្ចព្រមព្រៀងទន្លេមេគង្គ។ ដោយសាររដ្ឋាភិបាលទាំងអស់ធ្វើការតាមរយៈការពិភាក្សាគ្នា អំពីអនាគតនៃទំនប់សាយ៉ាប៊ូរី និងអំពីការចូលរួមរបស់ខ្លួនដើម្បីកិច្ចព្រមព្រៀងទន្លេមេគង្គ និងដើម្បីទន្លេមេគង្គ ដូច្នេះវានៅតែសំខាន់ដែលរដ្ឋាភិបាលនីមួយៗត្រូវអនុវត្តគោលការណ៍ស្មោះត្រង់នេះឱ្យមានប្រសិទ្ធភាពខ្ពស់ ដូចមានចែងនៅក្នុងមាត្រា ២៦ នៃអនុសញ្ញាទីក្រុងវៀណាស្តីពីច្បាប់នៃសន្ធិសញ្ញា ដែលតាមអនុសញ្ញានេះ "កិច្ចព្រមព្រៀងជាធរមាន

នីមួយៗត្រូវចងកាតព្វកិច្ចរបស់ភាគីទាំងអស់ ឱ្យគោរពតាម និងត្រូវគោរពដោយស្មោះត្រង់"។[៦៨] ក្នុងការកត់សម្គាល់ដូចគ្នានេះដែរបានបញ្ជាក់ថា នៅក្នុងកិច្ចព្រមព្រៀងទន្លេមេគង្គ គ្មានអ្វីដែលរារាំងភាគីដែលចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ មិនឱ្យស្នើសុំរកដំណោះស្រាយចំពោះវិវាទណាមួយពាក់ព័ន្ធនឹងទន្លេនេះតាមរយៈ ជំនួយ ឬការវិនិច្ឆ័យ ពីភាគីទីពីឡើយ។ ជាឧទាហរណ៍ រដ្ឋាភិបាលណាមួយក៏ដោយ ដែលស្ថិតនៅតាមដងទន្លេមេគង្គ អាចស្នើសុំឱ្យ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ចូលរួមជាមួយខ្លួន ក្នុងការតាមដានរួមគ្នាអំពីដំណោះស្រាយវិវាទ ទៅតាម មាត្រា២៧ នៃអនុសញ្ញាស្តីពីប្រព័ន្ធជីវសិរាង្គចម្រុះ (ការចរចា ការសម្របសម្រួល ការវិនិច្ឆ័យចំពោះមុខតុលាការយុត្តិធម៌អន្តរជាតិ ឬការសម្រុះសម្រួលគ្នា).

---

**កំណត់សម្គាល់:**

[១] *សូមមើល របាយការណ៍ស្តីពី "ការពិនិត្យលើទិដ្ឋភាពត្រី និងជម្រកត្រី នៅក្នុងការសិក្សាលទ្ធភាព និងផលប៉ះពាល់បរិស្ថានដែលបណ្តាលមកពីសំណើទំនប់ សាយ៉ាបួរីនៅលើទន្លេមេនៃទន្លេមេគង្គ*, ដោយ Eric Baran, Michel Larinier, Guy Ziv Gerd Marmulla (ចាប់ពីពេលនេះតទៅហៅថា Baran et al.), ទំព័រ៨ ដល់ទំព័រ១០ និងកំណត់សម្គាល់៤, (ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១១), (តារាងទី១នៃរបាយការណ៍នេះដែលអំពីលក្ខណៈសំខាន់ៗរបស់ទំនប់សាយ៉ាបួរី ដែលមានដូចជា ប្រវែង កម្ពស់ និងកម្រិតអាងប៉ាន់ប្រមាណ។ របាយការណ៍ស្រង់ និយមន័យនៃទំនប់ខ្នាតធំ របស់គណៈកម្មការអន្តរជាតិស្តីពីទំនប់ខ្នាតធំ ដែលផ្តល់និយមន័យថា "ទំនប់ខ្នាតធំ" ជាទំនប់ដែលមានកម្ពស់ចាប់ពី១៥ម៉ែត្រឡើងទៅ)។

[២] *ភាពស្របច្បាប់នៃការគំរាមកំហែង ឬការប្រើប្រាស់អាវុធនុយក្លេអែរ, មតិពិគ្រោះយោបល់*, ឆ្នាំ១៩៩៦ របស់តុលាការយុត្តិធម៌អន្តរជាតិ, ២២៦, ២៤១ ដល់២៤២, កថាខ័ណ្ឌ២៩ (ថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៩៩៦) (បញ្ជាក់បន្ថែម)។

[៣] កិច្ចព្រមព្រៀងទន្លេមេគង្គ ត្រូវគេស្គាល់ជាផ្លូវការថា "កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការដើម្បីកិច្ចការអភិវឌ្ឍន៍អាងទន្លេមេគង្គ ដោយមាននិរន្តរភាព", 34 I.L.M. 864 (ឆ្នាំ១៩៩៥)។ កិច្ចព្រមព្រៀងទន្លេមេគង្គជាសន្ធិសញ្ញាផ្នែកបរិស្ថានសំខាន់បំផុតដែលបង្កើតឡើងរវាងប្រទេសទាំងបួននៅតាមទន្លេមេគង្គ គឺប្រទេសកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រទេសថៃ និងប្រទេសវៀតណាម។

[៤] ការវិភាគនេះសន្មតថា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ជារដ្ឋាភិបាលដែលបានកំណត់ថា ដំណើរការនៃនីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ និងការព្រមព្រៀងជាមុន តាមកិច្ចព្រមព្រៀងទន្លេមេគង្គបានបញ្ចប់ ថាឯកសារយោងសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តអនុម័តគម្រោង ដូចជា របាយការណ៍ស្តីពីសិក្សាលទ្ធភាព របាយការណ៍ស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងរបាយការណ៍ស្តីពីការវាយតម្លៃផលប៉ះពាល់សង្គម មិនចាំបាច់ត្រូវសរសេរឡើងវិញ និងថា ការសាងសង់ទំនប់សាយ៉ាបួរី កំពុងដំណើរការ រួមទាំងការសង់ផ្លូវ និងខ្សែបញ្ជូន នៅក្បែរការដ្ឋានទំនប់។ ប្រសិនបើ មានការផ្លាស់ប្តូរព័ត៌មានអង្គហេតុនេះ សេចក្តីសន្និដ្ឋានផ្នែកច្បាប់នេះ អាចខុសគ្នា។

[៥] *សូមមើលឯកសាររបស់* Aaron T. Wolf, មានចំណងជើងថា *លក្ខណវិនិច្ឆ័យសម្រាប់ការបែកចែកស្មើភាពគ្នា: បេះដូងនៃទំនាស់ទឹកអន្តរជាតិ,* វេទិកាធនធានធម្មជាតិ 23, 3-30, ទំព័រ១៥ (ឆ្នាំ១៩៩៩) (កត់សម្គាល់ថា មានទីជម្រាលអន្តរជាតិចំនួន២៦១ និងថា

ទោះបីជាមានការលំបាក ក្នុងការចរចាសន្ធិសញ្ញាសម្រាប់(ទីជម្រាលនីមួយៗ) ក៏ដោយ ក៏សន្ធិសញ្ញាបែបនេះ បង្ហាញអំពីសេចក្តីត្រូវការ និងស្ថានភាពល្អបំផុតនៅថ្នាក់ជាតិ ព្រមទាំងមានអាទិភាពខ្ពស់បំផុតនៅក្នុងច្បាប់អន្តរជាតិ) ។

[៦] របាយការវាយតម្លៃនេះមាននៅលើគេហទំព័រ: http://www.internationalrivers.org/en/node/6424.

[៧] គណៈកម្មការទន្លេមេគង្គ, របាយការណ៍ស្តីពីការពិនិត្យឡើងវិញលើគម្រោងពិគ្រោះយោបល់ជាមុន, សំណើទំនប់សាយ៉ាប៊ូរី-ទន្លេមេគង្គ (ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១) ("របាយការណ៍ស្តីពីការពិនិត្យឡើងវិញលើគម្រោងពិគ្រោះយោបល់ជាមុន របស់គណៈកម្មការទន្លេមេគង្គ") ។

[៨] ទីភ្នាក់ងារថាមពលអន្តរជាតិ, *ការសិក្សាអំពីគោលការណ៍ណែនាំជាធរមាន, ក្របខ័ណ្ឌច្បាប់ និងនីតិវិធី សម្រាប់ការវាយតម្លៃផលប៉ះពាល់បរិស្ថានដោយសារគម្រោងវារីអគ្គិសនី ។ របាយការណ៍ស្តីពីបច្ចេកទេសវាយតម្លៃផលប៉ះពាល់បរិស្ថាន ។* ទីភ្នាក់ងារថាមពលអន្តរជាតិ-កិច្ចព្រមព្រៀងសម្រាប់អនុវត្តកម្មវិធី និងបច្ចេកវិទ្យាវារីអគ្គិសនី, ទំព័រ៣៥ (ឆ្នាំ២០០០) ។

[៩] *រោងចក្រផលិតបន្ទះក្ដារនៅទន្លេយូរ៉ាហ្គាយ (ប្រទេសអាហ្សង់ទីន និងប្រទេសយូរ៉ាហ្គាយ)* ទំព័រ៦០ ដល់ ៦១ កថាខណ្ឌ២០៤ (ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១០), សូមបើកមើលឯកសារនេះតាម: http://www.icj-cij.org/docket/files/135/15877.pdf. *សូមមើល* អនុសញ្ញាស្តីពីប្រព័ន្ធជីវសរីរាង្គចម្រុះផង, 1760 U.N.T.S. 79, 31 I.L.M. 818, មាត្រា ១៤, បើកឱ្យចុះហត្ថលេខា ថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៩៩២) (ចាប់ពីពេលនេះទៅ ហៅថា អនុសញ្ញាស្តីពីប្រព័ន្ធជីវសរីរាងចម្រុះ) (មាត្រា១៤ ពាក់ព័ន្ធនឹងកាតព្វកិច្ចក្នុងការវាយតម្លៃផលប៉ះពាល់ និងបន្ថយផលប៉ះពាល់ឱ្យនៅកម្រិតតិចបំផុត), សន្និសីទអង្គការសហប្រជាជាតិ ស្តីពីបរិស្ថាន និងកិច្ចការអភិវឌ្ឍន៍, សេចក្តីប្រកាសទីក្រុងរីយ៉ូ ស្តីពីបរិស្ថាន និងកិច្ចការអភិវឌ្ឍន៍, 31 I.L.M. 874 (ឆ្នាំ១៩៩២) (ចាប់ពីពេលនេះទៅហៅថា "សេចក្តីប្រកាសរីយ៉ូ") (តាមការបញ្ជាក់នៃគោលការណ៍ ១៧, ការវាយតម្លៃផលបះពាល់បរិស្ថានត្រូវអនុវត្តចំពោះបណ្តាសំណើសកម្មភាពដែលអាចមានផលប៉ះពាល់ ធ្ងន់ធ្ងរដល់បរិស្ថាន និងត្រូវស្ថិតក្រោមការសម្រេចចិត្តរបស់អាជ្ញាធរមានសមត្ថកិច្ចថ្នាក់ជាតិ") ។

[១០] អនុសញ្ញាស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន ក្នុងស្ថានភាពឆ្លងដែន, ឆ្នាំ១៩៨៩, U.N.T.S. 309, ៦៧ និងមាត្រា២, កថាខ័ណ្ឌ២ និង៣, *បើកឱ្យចុះហត្ថលេខា* នៅថ្ងៃ២៥ ខែកុម្ភៈ ឆ្នាំ១៩៩១ ។ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ មិនមែនជាហត្ថលេខីនៃសន្ធិសញ្ញានេះទេ ប៉ុន្តែអនុសញ្ញានេះ ពិតជាបង្ហាញទស្សនៈរបស់ប្រទេសជាច្រើន អំពីមុខងាររបស់ ការវាយតម្លៃផលប៉ះពាល់បរិស្ថាន ចំពោះគម្រោងអភិវឌ្ឍន៍ដែលគេដឹងថា មានផលប៉ះពាល់ឆ្លងដែន ។

[១១] Baran et al. ទំព័រ៤ ។

[១២] Baran et al. ពីទំព័រ៥ ដល់ទំព័រ៦ ។

[១៣] ការពិនិត្យឡើងវិញលើ ការវាយតម្លៃផលប៉ះពាល់បរិស្ថាន ដោយក្រុមហ៊ុន Ch. Karnchang Public Company Limited ដោយ Guy R. Lanza, គម្រោងវារីអគ្គិសនីសាយ៉ាប៊ូរី, សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ, ទំព័រ២, (ខែមេសា ឆ្នាំ២០១១) ។

[១៤] របាយការណ៍ ដោយ Zeb Hogan, ត្រីយក្សជិតផុតពូជ និងទំនប់ទម្លេមេ នៅអាងទន្លេមេគង្គៈ ការវាយតម្លៃស្ថានភាពបច្ចុប្បន្ន ការគំរាមកំហែង និងការកាត់បន្ថយផលប៉ះពាល់, ពីទំព័រ៨-៩ (ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១១) (បញ្ជាក់ថា ការវាយតម្លៃផលប៉ះពាល់បរិស្ថាន របស់ក្រុមហ៊ុនអភិវឌ្ឍន៍ពិតជាមិនគ្រប់ជ្រុងជ្រោយ និងមិនបានរាយការណ៍អំពីការខូចខាតពិតប្រាកដអំពីទំនប់សាយ៉ាប៊ូរីទេ" និងបញ្ជាក់ថា ការវាយ

តម្លៃផលប៉ះពាល់ថ្មីជាការចាំបាច់ ដែលដោះស្រាយផលប៉ះពាល់ត្រីដែលប្រឈមការគំរាមកំហែង និងត្រីពនាចរ ដោយសារទំនប់សាយ៉ាប្បូរី ។ ការឈមនឹងការខូចខាតអចិន្ត្រៃយ៍ចំពោះប្រព័ន្ធជីវសរីរាង្គចម្រុះនៅទន្លេមេគង្គ និងជលផលពីទន្លេមេគង្គ ពិតជាធំធេងណាស់ និងត្រូវចំណាយយ៉ាងខ្ពស់ សម្រាប់ការបន្តដំណើរការទៅមុខដោយផ្អែកលើព័ត៌មានមិនគ្រប់ជ្រុងជ្រោយនោះ" ។)

[១៥] របាយការណ៍ដោយ David J.H. Blake, យោបល់លើការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងការវាយតម្លៃផលប៉ះពាល់សង្គម, ឯកសារសម្រាប់គម្រោងវារីអគ្គិសនីសាយាប្បូរី, សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ពីទំព័រ២២ ដល់២៣ (ឯកសារបច្ចុប្បន្នកម្ម) (ដែលបញ្ជាក់ថា "ការវាយតម្លៃផលប៉ះពាល់បរិស្ថាន គ្របដណ្តប់វិសាលភាពភូមិសាស្ត្រតិចតួចបំផុតណាស់ដើម្បីរៀបចំឯកសារគ្រប់ជ្រុងជ្រោយ ដែលគេរំពឹងថា មានចម្ងាយរហូតដល់ច្រើនរយគីឡូម៉ែត្រទៅទន្លេលើ និងទន្លេក្រោម ។ ទំនប់នេះពិតជាមានផលប៉ះពាល់ និងផលវិបាកឆ្លងដែនយ៉ាងធ្ងន់ធ្ងរ ដោយលាតសន្ធឹងពីទន្លេមេចូលទៅប្រទេសថៃ កម្ពុជា និងប្រទេសវៀតណាម ដែលមិនត្រូវបានពិចារណានៅក្នុងរបាយការណ៍ស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម", "ការវាយតម្លៃផលប៉ះពាល់បរិស្ថានពិតជាមើលរំលងយ៉ាងឆ្ងាយវិសាលភាព និងទំហំនៃផលប៉ះពាល់ នៅគ្រប់វិស័យ តែពិសេស ជម្រកត្រី និងផ្នែកនៃធនធានទឹក ដែលមានសារសំខាន់ណាស់ចំពោះសុវត្ថិភាពស្បៀងអាហារ និងជីវភាពរស់នៅរបស់ប្រជាជនជាងពីរលាននាក់ដែលកំពុងរស់នៅតាមទន្លេមេនៃទន្លេមេគង្គ" និង "តាមស្ថានភាពបច្ចុប្បន្ន របាយការណ៍ស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមពិតជាមើលមិនបានវែងឆ្ងាយទេ ដែលជាទូទៅ និងតាមលក្ខណៈបច្ចេកទេសពិតជាឯកសារមិនត្រូវ ដែលនៅខ្វះកិច្ចការដែលត្រូវចុះស៊ើបអង្កេត ធ្វើការប៉ាន់ប្រមាណផលប៉ះពាល់ និងវិភាគផលប៉ះពាល់ដោយសារគម្រោង ដោយអន្លើនិងជាបណ្តោះអាសន្នលើជីវភាពរស់នៅរបស់ប្រជាជនដែលប្រឈមផលប៉ះពាល់ ដែលហេតុដូច្នេះហើយ គ្មានជំហរផ្តល់អនុសាសន៍ជូនវិធានការកាត់បន្ថយ និងទូទាត់សំណងសមរម្យឡើយ ។ ដំណើរការនៃការវាយតម្លៃទាំងមូល ហាក់ដូចជាគ្រាន់តែត្រូវបានអនុវត្តតាមរបៀបធ្វើលំហាត់គូសលើប្រអប់ចម្លើយតែប៉ុណ្ណោះ មិនមែនអនុវត្តដោយគោលបំណងហ្មត់ចត់ ដើម្បីបញ្ជាក់អះអាងអំពីផលប៉ះពាល់សង្គម និងបរិស្ថានពិតប្រាកដនោះទេ ។ នៅពេលព្រមគ្នានោះដែរ ជំនាញការដែលទទួលត្រូវក្នុងការសរសេរបាយការណ៍ស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន ហាក់ដូចជា ខ្វះសមត្ថភាពយ៉ាងខ្លាំង ក្នុងការអនុវត្ត ការងារវាយតម្លៃផលប៉ះពាល់បរិស្ថាន សម្រាប់គម្រោងទំនប់ទន្លេមេធំៗ តាមប្រព័ន្ធទន្លេឆ្លងដែនយ៉ាងសំខាន់នេះ") ។

[១៦] របាយការណ៍ស្តីពីការវាយតម្លៃឡើងវិញលើគម្រោងពិគ្រោះយោបល់ជាមុន របស់គណៈកម្មការទន្លេមេគង្គ ចំណុច ii ។

[១៧] ធម្មនុញ្ញពិភពលោកដើម្បីធម្មជាតិ, G.A. Res 37/7, U.N. GAOR, សម័យប្រជុំលើកទី៣៧ ត្រង់៤៥៥ ផ្នែក៣ កថាខ័ណ្ឌ១៦ (ថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨២) (ចាប់ពីពេលនេះទៅហៅថា "ធម្មនុញ្ញពិភពលោកដើម្បីធម្មជាតិ") ។

[១៨] *សូមមើល* គោលការណ៍ទី១០ នៃសេចក្តីប្រកាសទីក្រុងរីយ៉ូ ផង (សេចក្តីបញ្ជាក់បានបន្ថែម) (ដែលបញ្ជាក់ថា "នៅថ្នាក់ជាតិ <u>បុគ្គលម្នាក់ៗ</u> ត្រូវមានសិទ្ធិគ្រប់គ្រាន់ក្នុងការទទួលព័ត៌មានដែលពាក់ព័ន្ធនឹងបរិស្ថាន ដែល <u>គ្រប់គ្រងដោយអាជ្ញាធរសាធារណៈ</u>, រួមមានព័ត៌មានអំពី សកម្មភាពរបស់សហគមន៍ និងអំពីឱកាសចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត ។ <u>ប្រទេសនីមួយៗត្រូវសម្រួល និងជំរុញលើកទឹកចិត្តឱ្យមានការយល់ដឹង និងការចូលរួមជាសាធារណៈ ដោយធ្វើឱ្យមានព័ត៌មានយ៉ាងច្រើនសម្រាប់សាធារណជន</u> ...") និងគោលការណ៍ទី៩ (ដែលបញ្ជាក់ថា "ប្រទេសនីមួយៗ ត្រូវប្រកាសជូនដំណឹងជាមុន និងទាន់ពេលវេលា ព្រមទាំងត្រូវផ្តល់ព័ត៌មានពាក់ព័ន្ធជូនទៅប្រទេសដែលអាចប្រឈមផលប៉ះពាល់ អំពី

សកម្មភាពដែលអាចមានផលប៉ះពាល់បរិស្ថានឆ្លងដែនយ៉ាងធ្ងន់ធ្ងរ និងត្រូវពិគ្រោះយោបល់ជាមួយរដ្ឋទាំងនោះ តាំងពីដំបូង និង ដោយស្មោះត្រង់") ។

[១៩] *សូមមើល* អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រី, 1249 U.N.T.S. 13, មាត្រា៧ (b), *បើកឱ្យចុះហត្ថលេខា* ថ្ងៃទី១ ខែមីនា ឆ្នាំ១៩៨០ (សិទ្ធិចូលរួមក្នុងការរៀបចំនិងបង្កើតគោលនយោបាយរបស់រដ្ឋាភិបាល) និងមាត្រា១៤ កថាខ័ណ្ឌ២ (a) (សិទ្ធិចូលរួមក្នុងការរៀបចំផែនការអភិវឌ្ឍន៍), និង *សូមមើល* គោលការណ៍ទី២០នៃសេចក្តីប្រកាសទីក្រុងរីយ៉ូផង (ដែលបញ្ជាក់ថា "ស្ត្រីមានតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍បរិស្ថាន។ ហេតុដូច្នេះហើយ ការចូលរួមយ៉ាងពេលលេញរបស់ស្ត្រីសំខាន់ណាស់ដើម្បី សម្រេចជោគជ័យក្នុងការអភិវឌ្ឍន៍ដោយនិរន្តរភាព") ។

[២០] គណៈកម្មការទន្លេមេគង្គ: ការចូលរួមជាសាធារណៈតាមស្ថានភាពរបស់គណៈកម្មការទន្លេមេគង្គ, ត្រង់ចំណុច៣ (ឯកសារបច្ចុប្បន្នកម្ម) (បញ្ជាក់តាមច្បាប់ដើម) ។

[២១] គណៈកម្មការទន្លេមេគង្គ: ការចូលរួមជាសាធារណៈតាមស្ថានភាពរបស់គណៈកម្មការទន្លេមេគង្គ, ពីទំព័រ៨-៩ (ឯកសារបច្ចុប្បន្នកម្ម)

[២២] សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងក្រុមហ៊ុនអភិវឌ្ឍន៍គម្រោងជាក់ស្តែងពិតជាបានរៀបចំសកម្មភាពពិគ្រោះយោបល់ ជាសាធារណៈអំពីគម្រោងនេះ នៅពេលកំពុងរៀបចំធ្វើការវាយតម្លៃផលប៉ះពាល់បរិស្ថាន រវាងឆ្នាំ២០០៧ និងឆ្នាំ២០១០។ រហូតដល់ខែសីហា ឆ្នាំ២០១០ ការវាយតម្លៃ ផលប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គមគម្រោងនោះមិនត្រូវបានបញ្ចប់ទេ។ គណៈកម្មការទន្លេមេគង្គ, របាយការណ៍ស្តីពីការពិនិត្យឡើងវិញលើគម្រោងពិគ្រោះយោបល់ជាមុន, វ៉ុល២ ការពិគ្រោះយោបល់របស់ភាគីពាក់ព័ន្ធពាក់ព័ន្ធនឹងសំណើ គម្រោងទំនប់សាយ៉ាប៊ូរី ទំព័រ១៥ និងឧបសម្ព័ន្ធ៤: របាយការណ៍អំពីកិច្ចពិគ្រោះយោបល់ជាសាធារណៈ នៅសាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ (ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១) ("របាយការណ៍ពិនិត្យឡើងវិញលើកិច្ចពិគ្រោះយោបល់ជាមុន របស់គណៈកម្មការទន្លេមេគង្គ") ។

[២៣] *សូមមើល* របាយការណ៍ពិនិត្យឡើងវិញលើកិច្ចពិគ្រោះយោបល់ជាមុន របស់គណៈកម្មការទន្លេមេគង្គ ឧបសម្ព័ន្ធ៤ តារាង៧។

[២៤] *សូមមើល* របាយការណ៍ពិនិត្យឡើងវិញលើកិច្ចពិគ្រោះយោបល់ជាមុន របស់គណៈកម្មការទន្លេមេគង្គ ទំព័រ២ (កំណត់សម្គាល់ "មកដល់ត្រឹមថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១, អង្គសេចក្តីនៃអត្ថបទអំពីការសិក្សាលទ្ធភាពគម្រោងដែលបានដាក់ជូននោះ ត្រូវបានដាក់ឱ្យទាញ យកពីគេហទំព័រ: www.xayaburi.com ។ ចំណែកឯកសារផ្សេងៗទៀតដែលបានដាក់ជូនដែរ រួមទាំង របាយការណ៍ស្តីពីការវាយតម្លៃ ផលប៉ះពាល់បរិស្ថាន ពុំមានដាក់ជាសាធារណៈនៅពេលដែលយើងកំពុងសរសេរសេចក្តីព្រាងនៃរបាយការណ៍នេះទេ [បោះពុម្ពផ្សាយនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១]"។ នេះបង្ហាញថា មានលក្ខណៈល្អប្រសើរ ក្រោយពីបានបើក កិច្ចពិគ្រោះយោបល់ភាគីពាក់ព័ន្ធ នៅសាធារណរដ្ឋប្រជាធិតេយ្យប្រជាមានិតឡាវ) ។

[២៥] របាយការណ៍របស់ Blake, ទំព័រ១៥។

[២៦] នេះជាការកំណត់ដោយ សហជីពអន្តរជាតិដើម្បីអភិរក្សសម្បត្តិធម្មជាតិ នៅក្នុងបញ្ជីក្រហមរបស់សហជីពនេះ ដែលត្រូវបានទទួលស្គាល់យ៉ាងច្រើនថាជា គោលបំណងមួយ នៃវិធីសាស្ត្រពិភាពលោកក្នុងការវាយតម្លៃអំពីស្ថានភាពអភិរក្សប្រភេទពូជរុក្ខជាតិ និងសត្វ។ សម្រាប់ព័ត៌មានបន្ថែមអំពីបញ្ជីក្រហមរបស់សហជីពអន្តរជាតិដើម្បីអភិរក្សសម្បត្តិធម្មជាតិ ចូលទៅមើលតាមអាសយដ្ឋានគេហទំព័រ នេះ:

http://www.iucnredlist.org/ ។ ប្រភេទត្រី តាកសុន ត្រូវបានបញ្ចូលទៅក្នុងបញ្ជីថា ជាប្រភេទត្រី "ប្រឈមវិនាសផុតពូជ" ឬ "កម្រ" នៅពេលដែលគេចាត់ទុកថា វាត្រូវប្រឈមគ្រោះថ្នាក់វិនាសផុតពូជនៅក្នុងតំបន់ធម្មជាតិ ។ ដើម្បីមើលលក្ខណវិនិច្ឆ័យលម្អិតនៃការបញ្ចូលទៅក្នុងបញ្ជី, សូមមើល ជំពូក និងលក្ខណវិនិច្ឆ័យបញ្ចូលទៅក្នុងបញ្ជីក្រហម របស់សហជីពអន្តរជាតិដើម្បីអភិរក្សសម្បត្តិធម្មជាតិៈ ជំនាន់៣.១ ។ គណៈកម្មការសង្គ្រោះពូជត្រី នៃសហជីពអន្តរជាតិដើម្បីអភិរក្សសម្បត្តិធម្មជាតិ, សហជីពអន្តរជាតិដើម្បីអភិរក្សសម្បត្តិធម្មជាតិប្រចាំនៅសហគមន៍ គ្លែន (Gland), សហភាពស្វីស និងទីក្រុងខែមប្រីដ្ជ, ប្រទេសអង់គ្លេស, ពីទំព័រ១៦-២០ (ឆ្នាំ២០០១) ។

[២៧] របាយការណ៍របស់ Hogan, ទំព័រ១ (សម្រង់ផ្ទៃក្នុងត្រូវលុបចេញ) ។

[២៨] របាយការណ៍របស់ Hogan, ទំព័រ១ (សម្រង់ផ្ទៃក្នុងត្រូវលុបចេញ) ។

[២៩] របាយការណ៍របស់ Baran et al., ទំព័រ២១ ។

[៣០] របាយការណ៍របស់ Hogan, ទំព័រ១ ។

[៣១] អនុសញ្ញាស្តីពីប្រព័ន្ធជីវសិរីរាង្គចម្រុះ, មាត្រា២ កថាខ័ណ្ឌ១ ។

[៣២] អនុសញ្ញាស្តីពីប្រព័ន្ធជីវសិរីរាង្គចម្រុះ, មាត្រា៣ (ដែលបញ្ជាក់ថា "រដ្ឋនីមួយៗ តាមធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ និងគោលការណ៍នានាច្បាប់អន្តរជាតិ មានសិទ្ធិអធិបតេយ្យភាព ក្នុងការប្រើប្រាស់ធនធានរបស់ខ្លួនដោយគោរពទៅតាមគោលនយោបាយបរិស្ថាន និងទៅតាមការទទួលខុសត្រូវដើម្បីធានាថា សកម្មភាពអភិវឌ្ឍន៍នានានៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឬក្នុងការគ្រប់គ្រងរបស់ខ្លួន មិនបង្កការខូចខាតដល់បរិស្ថានរបស់ប្រទេសផ្សេងៗ ឬតំបន់ដែលស្ថិតនៅក្រៅដែនសមត្ថកិច្ចជាតិរបស់ខ្លួនឡើយ") ។

[៣៣] របាយការណ៍របស់ Baran et al. ទំព័រ១៥ ។

[៣៤] របាយការណ៍របស់ Baran et al. ទំព័រ១៦ ។

[៣៥] របាយការណ៍របស់ Baran et al. ទំព័រ២៣ ។

[៣៦] របាយការណ៍របស់ Baran et al. ទំព័រ២៣ ។

[៣៧] របាយការណ៍របស់ Baran et al. ទំព័រ១៧-១៨ ។ (សម្រង់ផ្ទៃក្នុងត្រូវលុបចេញ) ។

[៣៨] របាយការណ៍របស់ Baran et al. ទំព័រ១៨ ។

[៣៩] របាយការណ៍របស់ Baran et al. ទំព័រ២៦ ។

[៤០] របាយការណ៍របស់ Baran et al. ទំព័រ២៦ ។

[៤១] របាយការណ៍របស់ Baran et al. ទំព័រ២៦ ។

[៤២] របាយការណ៍របស់ Baran et al. ទំព័រ២៧ ។

[៤៣] របាយការណ៍របស់ Baran et al. ទំព័រ៣0 ។

[៤៤] របាយការណ៍របស់ Hogan, ទំព័រ៨ ។

[៤៥] របាយការណ៍របស់ Hogan, ទំព័រ២៣ ។

[៤៦] ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ អំពីទន្លេមេនៃទន្លេមេគង្គ, ដែលត្រូវបានរៀបចំសម្រាប់គណៈកម្មការទន្លេមេគង្គ ដោយមជ្ឈមណ្ឌលអន្តរជាតិ ដើម្បីការគ្រប់គ្រងបរិស្ថាន, ទំព័រ២៤ (ខែតុលា ឆ្នាំ២០១០) ។

[៤៧] *នីតិភាពនៃការគំរាមកំហែង ឬការប្រើប្រាស់អាវុធនុយក្លេអ៊ែរ* ទំព័រ២៤១-២៤២, កថាខណ្ឌ២៩ ។ គោលការណ៍នេះក៏មានមូលដ្ឋាននៅក្នុងទ្រឹស្តីពីរដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទាក់ទងនឹងច្បាប់អនុវត្តចំពោះទន្លេឆ្លងដែនគឺៈ ទ្រឹស្តីអធិបតេយ្យដែនដីមានកម្រិត និងទ្រឹស្តីសហគមន៍ ។ តាមទ្រឹស្តីទី១ៈ "ប្រទេសមួយអាចប្រើជាប្រយោជន៍ នូវទឹកដែលហូរកាត់ដែនដីរបស់ខ្លួន ទៅតាមកម្រិតដែល ការប្រើប្រាស់នោះមិនរំខានដល់ការប្រើប្រាស់ទឹកសមហេតុផល ដោយប្រទេសនានានៅទន្លេក្រោមទេ" ។ តាមទ្រឹស្តីសហគមន៍ "ទឹកពីអាងបង្ហូរទឹកត្រូវគ្រប់គ្រងជាផ្ទៃទឹកមួយ ដោយមិនគិតអំពីព្រំដែននៃដែនដីជាតិឡើយ ។ ប្រទេសនានានៅតាមដងទន្លេត្រូវគ្រប់គ្រង និងធ្វើអាងបង្ហូរទឹករួមគ្នា ព្រមទាំងទទួលផលប្រយោជន៍ពីអាងបង្ហូរទឹកនេះរួមគ្នា" ។ របាយការណ៍របស់ Aaron Schwabach, កំពប់ជាតិគីនៅសាន់ដូស (*The Sandoz Spil*)ៈ *ច្បាប់អន្តរជាតិខកខានមិនបានការពារ ការបំពុលបរិស្ថាននៅទន្លេរ៉ាញ*, 16 ECOLOGY L. Q. 443, 456 និង 458 (ឆ្នាំ១៩៨៩), *សូមមើល* របាយការណ៍របស់ William W. Van Alstyneៈ *ច្បាប់អន្តរជាតិ និងវិវាទទន្លេអន្តរប្រទេស*, 48 CAL. L. REV. 596, 616 (ឆ្នាំ1960), សម្រង់របស់ H.A. SMITHៈ ការប្រើប្រាស់ទន្លេអន្តរជាតិជាប្រយោជន៍សេដ្ឋកិច្ច, ទំព័រ 150-151 (ឆ្នាំ 1931) (ប្រព័ន្ធទឹកទន្លេនីមួយៗគឺជាផ្ទៃទឹករូបវន្តធម្មជាតិមួយដែលមិនអាចបំបែកបាន និងដោយហេតុនេះគេត្រូវអភិវឌ្ឍវា ដើម្បីប្រើប្រាស់ជាសេវាកម្មដែលមានលទ្ធភាពខ្ពស់បំផុតសម្រាប់សហគមន៍ទាំងមូល ដោយមិនគិតថា សហគមន៍នោះត្រូវបែងចែកជាដែនសមត្ថកិច្ចនយោបាយពីរ ឬច្រើនឡើយ" ។

[៤៨] ធម្មនុញ្ញពិភពលោកដើម្បីធម្មជាតិ, ផ្នែក៣ កថាខ័ណ្ឌ២១ (d) ។

[៤៩] សន្ធិសញ្ញាមិត្តភាពនិងសហប្រតិបត្តិការនៅតំបន់អាស៊ីអាគ្នេយ៍, 27 I.L.M. 610 (ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៧៦), អាចបើកមើលបានតាមៈ http://www.asean.org/1217.htm ។ (តាមមាត្រា១០ ចែងថាៈ "ភាគីចុះកិច្ចសន្យាកម្រិតខ្ពស់ ទោះជាក្នុងរូមភាព មិនត្រូវ ចូលរួមក្នុងសកម្មភាពណាមួយ ដែលជាហេតុបណ្តាលឱ្យមានការគំរាមកំហែងដល់ស្ថិរភាពនយោបាយ និងសេដ្ឋកិច្ច អធិបតេយ្យភាព ឬបូរណភាព ដែនដីរបស់ភាគីចុះកិច្ចសន្យាដទៃទៀតទេ") ។ *សូមមើល* អនុសញ្ញាស្តីពីច្បាប់ប្រើប្រាស់ផ្លូវទឹកអន្តរជាតិដែលមិនមែនជាផ្លូវនាវាចរណ៍ 36 I.L.M. 700, ផ្នែក៤, មាត្រា២០, *បើកឱ្យចុះហត្ថលេខា* ថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៧ (ចាប់ពីពេលនេះទៅហៅថា អនុសញ្ញាស្តីពីច្បាប់ប្រើប្រាស់ផ្លូវទឹកអន្តរជាតិដែលមិនមែនជាផ្លូវនាវាចរណ៍) (រដ្ឋដែលមានផ្លូវទឹក ត្រូវការពារ និងរក្សាប្រព័ន្ធសរីរាង្គធម្មជាតិ នៃផ្លូវទឹកអន្តរជាតិ រៀងៗខ្លួន ឬក្នុងកាលៈទេសៈសមស្រប ត្រូវរួមគ្នាការពារ") ។ មាត្រា៧ ផ្នែក២ នៃ អនុសញ្ញាស្តីពីច្បាប់ប្រើប្រាស់ផ្លូវទឹកអន្តរជាតិដែលមិនមែនជាផ្លូវនាវាចរណ៍ៈ ("១. រដ្ឋដែលមានផ្លូវទឹក ក្នុងការប្រើប្រាស់ផ្លូវទឹកអន្តរជាតិនៅក្នុងដែនដីរបស់ខ្លួន ត្រូវចាត់វិធានការសមស្របដើម្បីការពារកុំឱ្យមានបង្កការខូចខាតធ្ងន់ធ្ងរដល់រដ្ឋដែលមានផ្លូវទឹកផ្សេងទៀត ។ ២. ប៉ុន្តែ ប្រសិនបើ មានបង្កការខូចខាតធ្ងន់ធ្ងរដល់រដ្ឋដែលមានផ្លូវទឹកផ្សេងទៀត ដូច្នេះរដ្ឋដែលការប្រើប្រាស់របស់ខ្លួនបណ្តាលឱ្យមានការខូចខាតនោះ ក្នុងពេលដែលគ្មានកិច្ចព្រមព្រៀងចំពោះការប្រើប្រាស់បែបនេះ ត្រូវចាត់វាល់វិធានការសមស្រប ដោយគោរពទៅតាមបទបញ្ញត្តិនៃមាត្រា៥ [ការចូលរួម និងការប្រើប្រាស់ សមហេតុផល និងស្មើភាពគ្នា] និងមាត្រា៦

[កត្តានានាដែលពាក់ព័ន្ធនឹងការប្រើប្រាស់សមហេតុផល និងស្មើភាពគ្នា], ក្នុងការពិគ្រោះយោបល់ជាមួយរដ្ឋដែលប្រឈមផលប៉ះពាល់ ដើម្បីបំបាត់ឬកាត់បន្ថយគ្រោះថ្នាក់នោះ ទៅតាមស្ថានភាពសមស្រប ដើម្បីពិភាក្សាអំពីបញ្ហាសំណង")។

[៥០] *Gabcikovo-Nagymaros Project (Hungary/Slovakia)*, 1997 I.C.J. 7, 54, para. 78 (1997).

[៥១] គម្រោង *Gabcikovo-Nagymaros* (*ប្រទេសហុងគ្រី និងប្រទេសស្លូវ៉ាគី*) ទំព័រ៥៦ កថាខណ្ឌ៨៥។ (បញ្ជាក់បន្ថែម)

[៥២] កិច្ចព្រមព្រៀងទន្លេមេគង្គ, ផ្នែក២, ខ៨។

[៥៣] *សូមមើល* ធម្មនុញ្ញពិភពលោកដើម្បីធម្មជាតិ, ផ្នែក២, ១១ (បញ្ជាក់បន្ថែម) (បង្ហាញគោលការណ៍នេះបន្ថែមទៀតថា "ត្រូវគ្រប់គ្រងបណ្តាសកម្មភាព ដែលអាចមានផលប៉ះពាល់លើធម្មជាតិ និងត្រូវប្រើបច្ចេកវិទ្យាដែលអាចជួយបន្ថយហានិភ័យ ឬផលប៉ះពាល់យ៉ាងខ្លាំងផ្សេងទៀតដល់ធម្មជាតិ, ជាពិសេស (ក) ត្រូវបញ្ចៀសបណ្តាសកម្មភាពដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់ដែលមិនអាចកែប្រែបានដល់ធម្មជាតិ (ខ) ត្រូវពិនិត្យមុនយ៉ាងហ្មត់ចត់ ចំពោះបណ្តាសកម្មភាពដែលអាចបង្កឱ្យមានហានិភ័យយ៉ាងខ្លាំងដល់ធម្មជាតិ, អ្នកគាំទ្រគម្រោងត្រូវបង្ហាញថាប្រយោជន៍ដែលរំពឹងថានឹងទទួលបាននោះ សំខាន់ជាងការខូចខាតយ៉ាងធ្ងន់ធ្ងរដល់សម្បត្តិធម្មជាតិ និងនៅទីណាដែលគ្មានការយល់ដឹងយ៉ាងពេញលេញ អំពីផលប៉ះពាល់ធ្ងន់ធ្ងរនោះទេ ពេលនោះមិនត្រូវបន្តសកម្មភាពទាំងនោះទេ, (គ) ចំពោះសកម្មភាពទាំងឡាយណាដែលអាចរំខានដល់សម្បត្តិធម្មជាតិ ត្រូវតែមានការវាយតម្លៃជាមុនអំពីផលវិបាករបស់វា និងត្រូវធ្វើការសិក្សាអំពីផលប៉ះពាល់បរិស្ថានដែលបណ្តាលមកពីគម្រោងអភិវឌ្ឍន៍ ដោយមានប្រសិទ្ធភាពជាមុន និងប្រសិនបើ ត្រូវអនុវត្តជាក់ស្តែង សកម្មភាពទាំងនោះត្រូវមានផែនការ និងត្រូវអនុវត្តដើម្បីកាត់បន្ថយផលប៉ះពាល់ធ្ងន់ធ្ងរទាំងនោះ ឱ្យថយនៅកម្រិតទាបបំផុត ...”), ឯកសាររបស់ David A. Wirth: *សេចក្តីប្រកាសទីក្រុងរីយ៉ូស្តីពីបរិស្ថាន និងគម្រោងអភិវឌ្ឍន៍: ពីរជំហានទៅមុខ មួយជំហានថយក្រោយ ឬមួយជំហានទៅមុខ ពីជំហានថយក្រោយ?* 29 GA. L. REV. 599, 634 (ឆ្នាំ 1995) (សម្រង់ផ្ទៃក្នុងត្រូវលុបចេញ) (ពន្យល់ថា "វិធីសាស្ត្រគិតបង្ការទុកមុនមានជាប់ជាមួយទស្សនៈអំពីការអភិវឌ្ឍដោយនិរន្តរភាព បើតាមការសន្មត ដោយសារការគិតបង្ការទុកមុនជាផ្នែកនៃបន្ទុកភស្តុតាងដែលចាំបាច់ត្រូវបង្កើតឡើង ដែលជាពិសេស ការសម្រេចចិត្តលើគម្រោងអភិវឌ្ឍន៍បំពេញសេចក្តីត្រូវការនាពេលបច្ចុប្បន្ន ដែលទន្ទឹមគ្នានេះ ឆ្លើយតបនឹងកម្រិតបរិស្ថានបច្ចុប្បន្ន និងរក្សានូវលទ្ធភាពរបស់មនុស្សជំនាន់ក្រោយដើម្បីបំពេញសេចក្តីត្រូវការរបស់គេ”)។

[៥៤] របាយការណ៍ស្តីពីការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ, ទំព័រ៤។

[៥៥] របាយការណ៍ស្តីពីការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ, ទំព័រ៤។

[៥៦] មាត្រា៥៩នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ១៩៩៣, វិសោធនកម្ម ឆ្នាំ១៩៩៩) ចែងថា "រដ្ឋត្រូវការពារបរិស្ថាន និងតុល្យភាពនៃភោគទ្រព្យធម្មជាតិ និងបង្កើតផែនការច្បាស់លាស់ក្នុងការគ្រប់គ្រង ដី ទឹក អាកាស ខ្យល់ ភូគព្ភសាស្ត្រ ប្រព័ន្ធជីវសាស្ត្រ ធម្មជាតិ រ៉ែ ថាមពល ប្រេងសាំងនិងឧស្ម័ន ថ្មនិងខ្សាច់ ត្បូង ព្រៃនិងអនុផលព្រៃឈើ សត្វព្រៃ ត្រី និងធនធានជលផល"។

[៥៧] មាត្រា១៩នៃរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ (ឆ្នាំ២០០៣) បញ្ជាក់ថា "ប្រជាជន និងអង្គការទាំងអស់ ត្រូវតែការពារធនធានបរិស្ថាន និងធនធានធម្មជាតិ ដូចជា: ផ្ទៃដី សម្បត្តិក្រោមដី ព្រៃ សត្វ ប្រភពទឹក និងបរិយាកាស"។

[៥៨] ផ្នែក៨៥នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រថៃ (ឆ្នាំ២០០៧) បញ្ជាក់ថា "រដ្ឋត្រូវគោរព គោលនយោបាយស្តីពីការប្រើប្រាស់ដី ធនធានធម្មជាតិ និងបរិស្ថាន ដូចខាងតទៅ: ... (៥) អនុវត្តការជំរុញ អភិរក្ស និងការពារគុណភាពនៃបរិស្ថានទៅតាមគោលការណ៍អភិវឌ្ឍន៍ដោយនិរន្តរភាព, និងលើកទឹកចិត្តសាធារណជន ប្រជាសហគមន៍ និងរដ្ឋបាលមូលដ្ឋាន ឱ្យចូលរួមក្នុងការកំណត់វិធានការនានា" ។ *សូមមើល* ផ្នែក៧៣ផង ("បុគ្គលម្នាក់ៗត្រូវមានកាតព្វកិច្ចក្នុង ... ការរក្សាធនធានធម្មជាតិ និងបរិស្ថានដូចមានចែងបទបញ្ញត្តិច្បាប់") ។

[៥៩] មាត្រា២៩នៃរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋសង្គមនិយមវៀតណាម (ឆ្នាំ១៩៩២, វិសោធនកម្ម ឆ្នាំ២០០១) ចែងថា "អង្គការរដ្ឋ ... និងបុគ្គលទាំងអស់ត្រូវតែគោរពច្បាប់របស់រដ្ឋ ស្តីពីការប្រើប្រាស់សមស្របនូវសម្បត្តិធម្មជាតិ និងស្តីពីការការពារបរិស្ថាន។ រាល់អំពើទាំងឡាយដែលអាចបណ្តាលឱ្យបាត់បង់សម្បត្តិធម្មជាតិ និងធ្វើឱ្យខូចខាតដល់បរិស្ថាន ត្រូវហាមឃាត់ជាដាច់ខាត" ។

[៦០] គណៈកម្មការទន្លេមេគង្គកម្ពុជា នីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ និងការយល់ព្រមជាមុន ទម្រង់សម្រាប់ឆ្លើយតបចំពោះការពិគ្រោះយោបលជាមនុ ទំព័រ៣ (ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១១) ។

[៦១] គណៈកម្មការទន្លេមេគង្គថៃ នីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ និងការយល់ព្រមជាមុន ទម្រង់សម្រាប់ឆ្លើយតបចំពោះការពិគ្រោះយោបលជាមនុ ទំព័រ២ (ខែមេសា ឆ្នាំ២០១១) ។

[៦២] គណៈកម្មការទន្លេមេគង្គវៀតណាម នីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ និងការយល់ព្រមជាមុន ទម្រង់សម្រាប់ឆ្លើយតបចំពោះ ការពិគ្រោះយោបលជាមនុ ទំព័រ៣ (ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១១) ។

[៦៣] គម្រោង Gabcikovo-Nagymaros (ប្រទេសហុងគ្រី និង ស្លូវ៉ាគី) ទំព័រ៨១ កថាខ័ណ្ឌ ១៥២, *សូមមើល* គោលការណ៍ទី១៦នៃសេចក្តីប្រកាសទីក្រុងរីយ៉ូ (រដ្ឋបាលថ្នាក់ជាតិត្រូវ "ខិតខំប្រឹងប្រែងជំរុញការធ្វើឱ្យការខូចខាតផ្នែកបរិស្ថានទៅជារឿងខាងក្នុង និងការប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុ ដោយពិចារណាអំពីវិធីសាស្ត្រដែលអ្នកធ្វើឱ្យខូចបរិស្ថាន ជាគោលការត្រូវទទួលបន្ទុកលើការខូចខាតបរិស្ថាន ដោយគោរពទៅតាមផលប្រយោជន៍សាធារណៈ និងដោយធ្វើឱ្យខូចទម្រង់ ពាណិជ្ជកម្ម និងគម្រោងវិនិយោគអន្តរជាតិ") ។

[៦៤] មាត្រា៧ (បញ្ជាក់បន្ថែម) (ភាគីទាំងអស់យល់ព្រម "ព្យាយាមប្រឹងប្រែងបញ្ចៀស កាត់បន្ថយ និងសម្រាលផលប៉ះពាល់ ដែលអាចកើតមានចំពោះបរិស្ថាន ជាពិសេសចំពោះ បរិមាណនិងគុណភាពទឹក, លក្ខខណ្ឌប្រព័ន្ធសរីរាង្គធម្មជាតិ និងតុល្យភាពសរីរាង្គធម្មជាតិនៃប្រព័ន្ធទន្លេ ពីការអភិវឌ្ឍ និងការប្រើប្រាស់អាងទន្លេមេគង្គ ឬការបញ្ចេញកាកសំណល់ និងការហូរត្រឡប់មកវិញ។ នៅពេលដែលរដ្ឋមួយ ឬច្រើនទទួលបានសេចក្តីជូនដំណឹងអមដោយភស្តុតាងត្រឹមត្រូវ និងមានសុពលភាពថា វាកំពុងបង្កការខូចខាតយ៉ាងជាក់ស្តែងចំពោះប្រទេសណាមួយ ឬច្រើនដែលស្ថិតនៅតាមដងទន្លេមេគង្គ ដោយសារការប្រើប្រាស់ ឬការបញ្ចេញកាកសំណល់ចូលទៅក្នុងនៃទន្លេមេគង្គ ដូច្នេះរដ្ឋនោះ ត្រូវតែបញ្ឈប់ជាបន្ទាន់នូវបុព្វហេតុនៃការបង្កការខូចខាតដូចការចោទប្រកាន់នោះ រហូតដល់បុព្វហេតុនៃការបង្កការខូចខាតនោះ ត្រូវបានកំណត់ទៅតាម មាត្រា៨" ។

[៦៥] មាត្រា៨ (បញ្ជាក់បន្ថែម) (ភាគីទាំងអស់យល់ព្រមថា "នៅទីណាដែលផលប៉ះពាល់បង្កឱ្យមានការខូចខាតជាក់ស្តែងចំពោះប្រទេសណាមួយ ឬចំពោះប្រទេសជាច្រើន ដែលរស់នៅតាមដងទន្លេមេគង្គ ដោយសារការប្រើប្រាស់ និងការកាកសំណល់ទៅក្នុងទឹកនៃទន្លេមេគង្គ ដោយរដ្ឋណាមួយដែលស្ថិតនៅតាមដងទន្លេ ដូច្នេះភាគីដែលពាក់ព័ន្ធ ត្រូវកំណត់ឱ្យច្បាស់លាស់អំពីកត្តាពាក់ព័ន្ធទាំងអស់ បុព្វហេតុ ទំហំនៃការខូចខាត និងការទទួលខុសត្រូវចំពោះការខូចខាតដែលបណ្តាលមកពីរដ្ឋនោះ ដោយស្របទៅតាមគោលការណ៍នៃច្បាប់អន្តរជាតិដែលពាក់ព័ន្ធនឹង

ការទទួលខុសត្រូវរបស់រដ្ឋ, និងដើម្បីពិចារណា ដោះស្រាយបញ្ហា មតិខ្វែងគំនិតគ្នា និងវិវាទទាំងអស់ ទៅតាមលក្ខណៈមិត្តភាព និងទាន់ពេលវេលា ដោយសន្តិវិធី ដូចមានចែងនៅក្នុងមាត្រា៣៤ និង៣៥ នៃកិច្ចព្រមព្រៀងនេះ និងអនុលោមទៅតាម ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ")។

[៦៦] គណៈកម្មការពិភពលោកទទួលបន្ទុកទំនប់, ទំនប់និងគម្រោងអភិវឌ្ឍន៍: ក្របខ័ណ្ឌថ្មីសម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត, ២២៩-២៣០ (ខែវិច្ឆិកា ឆ្នាំ២០០០) (កំណត់សម្គាល់ខាងក្រុងត្រូវលុបចេញ, បញ្ជាក់បន្ថែម)។

[៦៧] ចំណុចនេះក៏ត្រូវគ្នានឹងគោលការណ៍ទី១៣ នៃសេចក្តីប្រកាសទីក្រុងរីយ៉ូដែរ ដែលបញ្ជាក់ថា: "រដ្ឋនីមួយៗត្រូវរៀបចំតាក់តែង ច្បាប់ជាតិពាក់ព័ន្ធនឹងការទទួលខុសត្រូវ និងសំណងចំពោះជនរងគ្រោះនៃការបំពុលបរិស្ថាន និងការខូចខាតផ្នែកបរិស្ថានផ្សេងៗទៀត។ រដ្ឋនីមួយៗ ក៏ត្រូវតែសហការគ្នាក្នុងលក្ខណៈជំរុញ និងប្តេជ្ញាចិត្តកាន់តែខ្ពស់ដើម្បីរៀបចំតាក់តែងច្បាប់អន្តរជាតិបន្ថែមទៀត ពាក់ព័ន្ធនឹងការទទួលខុសត្រូវ និងសំណងចំពោះផលប៉ះពាល់ធ្វើឱ្យខូចខាតបរិស្ថាន ដោយសារសកម្មភាពអនុវត្តគម្រោងនានានៅក្នុងដែនសមត្ថកិច្ច និងការគ្រប់គ្រងតំបន់ដែលស្ថិតនៅក្រៅដែនសមត្ថកិច្ចរបស់ខ្លួន"។

[៦៨] អនុសញ្ញាទីក្រុងវេណាស្តីពីច្បាប់សន្ធិសញ្ញា, មាត្រា២៦, 1155 U.N.T.S. 331, បើកឱ្យចុះហត្ថលេខា ខែឧសភា ឆ្នាំ១៩៦៩។